ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា
# ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

# ការប្រមូលអាករបំភ្លឺសាធារណៈរបស់
# អគ្គនាយកដ្ឋានពន្ធដារ

PUBLIC LIGHT TAX COLLECTION AT GENERAL DEPARTMENT OF TAXATION

ជំនាញ: សវនកម្ម

រៀបរៀងដោយ៖ ស៊ឹម បញ្ញា

អត្តលេខ: MA 20/013

ឆ្នាំសិក្សា ៖ ឆ្នាំ២០២២ - ២០២៤

ក្រសួងអប់រំយុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា
# ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

# ការប្រមូលអាករបំភ្លឺសាធារណៈរបស់
# អគ្គនាយកដ្ឋានពន្ធដារ

PUBLIC LIGHT TAX COLLECTION AT GENERAL DEPARTMENT OF TAXATION

ជំនាញ: សវនកម្ម

សាស្ត្រាចារ្យណែនាំ ៖ បណ្ឌិត កង ឱម

បេក្ខបណ្ឌិត យ៉ាក ឌុទ្ធី

ឆ្នាំសិក្សា ៖ ឆ្នាំ២០២២ - ២០២៤

**គណៈកម្មការត្រួតពិនិត្យរបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា**

**ប្រធានបទ៖ ការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ**

| | |
|---|---|
| សាស្ត្រាចារ្យណែនាំ | សាស្ត្រាចារ្យណែនាំ |
| បេក្ខបណ្ឌិត យ៉ាក វុទ្ធី | បណ្ឌិត កង ឱម |
| គណៈកម្មការអភិវឌ្ឍន៍កម្មវិធីសិក្សា និងស្រាវជ្រាវ<br>ប្រធាន | ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ |
| បណ្ឌិត ហ៊ូ គុជគន្ធលីនណា | បណ្ឌិត សេង សំអឿន |

**នាយកវិទ្យាស្ថាន**

**បណ្ឌិត ហេង វ៉ាន់ដា**

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញសវនកម្ម នៅវិទ្យាស្ថានវ៉ាន់ដា អស់រយៈពេល២ ឆ្នាំសិក្សារួចមក ខ្ញុំបាទបានទទួលនូវចំណេះដឹងជាច្រើន ដែលពាក់ព័ន្ធនឹងមុខវិជ្ជាសវនកម្ម គណនេយ្យ ពន្ធ ជាពិសេសយល់ច្បាស់ថាជំនាញសវនកម្ម គឺជាជំនាញមួយដ៏មានសារៈសំខាន់ សម្រាប់តម្រូវការស្ថាប័នទាំងអស់ មិនថាស្ថាប័នរដ្ឋ ស្ថាប័នឯកជន ឬអង្គការក្រៅរដ្ឋាភិបាលឡើយ។ ក្នុងនោះផងដែរដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែស៊ីជម្រៅលើជំនាញរបស់ខ្លួន វិទ្យាស្ថានក៏បានបញ្ចូលមុខវិជ្ជាជាច្រើន ដែលពាក់ព័ន្ធទៅនឹងកម្មវិធីសិក្សាទៅតាមកម្រិត ពីឆ្នាំសិក្សាទីមួយ រហូតដល់ឆ្នាំសិក្សាទីពីរដែលត្រូវបញ្ចប់ការសិក្សា។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែជាយានសម្រាប់ឱ្យនិស្សិតយកទៅប្រើប្រាស់ នៅក្នុងវិស័យការងារបាន ជាពិសេសនោះ គឺមុខវិជ្ជាពន្ធដែលស្ថាប័នត្រូវឱ្យបុគ្គលិកពាក់ព័ន្ធត្រូវមានចំណេះដឹង ដើម្បីរៀបចំ និងកាន់កាប់បញ្ជី និងរបាយការណ៍ឱ្យបានត្រឹមត្រូវ ស្របទៅតាមការណែនាំរបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីជៀសវាងនូវបញ្ហាផ្សេងៗដែលអាចកើតមានឡើង និងធ្វើឱ្យមានការរាំងស្ទះដល់ដំណើរការអាជីវកម្មទៅថ្ងៃក្រោយ។

ដោយខ្ញុំបាទយល់ថាចំណេះដឹងខាងពន្ធ ជាចំណេះដឹងបន្ថែមមួយទៀតដ៏មានសារៈសំខាន់ សម្រាប់សវនករទាំងអស់ធ្វើការសិក្សាស្វែងយល់ និងស្របពេលដែលខ្ញុំបាទមានឱកាសបានសរសេររបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផងនោះ ទើបខ្ញុំបាទសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី **«ការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយដ្ឋានពន្ធដារ»** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជារបាយការណ៍ក្នុងគោលបំណងឱ្យអ្នកអាន និងអ្នកស្រាវជ្រាវក្រោយៗទៀតឱ្យយល់កាន់តែច្បាស់ពីពន្ធ។

ខ្ញុំបាទសង្ឃឹមថា ការរៀបចំរបាយការណ៍ស្រាវជ្រាវនេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកដទៃទៀត ដែលមានបំណងលើការសិក្សាពីជំនាញពន្ធដារ។

ជាទីបញ្ចប់ខ្ញុំបាទ សូមមេត្តាខន្តីអភ័យទោសពីសំណាក់សាស្ត្រាចារ្យ រាមច្បង និងមិត្តអ្នកអាន នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនានៅក្នុងរបាយការណ៍ស្រាវជ្រាវនេះ ហើយខ្ញុំបាទរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយៗទៀតមានភាពល្អប្រសើរ។

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី២០ ជំនាញសវនកម្មនៃវិទ្យាស្ថាន វ៉ាន់ដា

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖**

លោកឪពុក និងអ្នកម្ដាយដែលបានផ្ដល់កំណើត ហើយខិតខំបីបាច់ថែរក្សាកូន ព្រមទាំងផ្គត់ផ្គង់ដល់កូនសព្វបែបយ៉ាង ខិតខំលើកទឹកចិត្តកូនក្នុងការសិក្សា តាំងពីកូនចូលរៀនដំបូងរហូតមកដល់ពេលនេះ និងបានបង្រៀនកូនឱ្យចេះស្នេហាជាតិមាតុភូមិកម្ពុជា។

នាយក គណៈគ្រប់គ្រង បុគ្គលិក សាស្ត្រាចារ្យនៃវិទ្យាស្ថាន វ៉ាន់ដា ដែលជានិច្ចកាលតែងតែផ្ដល់នូវការលើកទឹកចិត្ត អនុគ្រោះដល់ខ្ញុំបាទរហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ជាពិសេសសាស្ត្រាចារ្យ **បណ្ឌិត កង ឱម** និងសាស្ត្រាចារ្យ **យ៉ាក ខុន្ធី** ដែលលោកបានឆ្លៀតពេលវេលាដ៏មានតម្លៃ ដើម្បីជួយណែនាំដល់ការសរសេររបាយការណ៍របស់ខ្ញុំបាទឱ្យរឹតតែមានភាពល្អប្រសើរ។

ជាទីបញ្ចប់ខ្ញុំបាទ សូមលើកដៃសំពះបួងសួងដល់គុណព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោកជួយបីបាច់ថែរក្សាដល់លោកអ្នកមានគុណខាងលើឱ្យជួបតែសេចក្ដីសុខគ្រប់ប្រការកុំបីអាក់ខានឡើយ។

សូមគោរពជូនពរដល់គុណូបការជនទាំងអស់ សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ ដ៏មហាប្រសើរ គឺះ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ខ្ញុំបាទសូមធានាអះអាង និងទទួលខុសត្រូវលើខ្លឹមសារនៅក្នុងរបាយការណ៍ស្រាវជ្រាវនេះថា របាយការណ៍ស្រាវជ្រាវនេះ គឺជាស្នាដៃស្រាវជ្រាវផ្ទាល់របស់ខ្ញុំបាទ ដោយគ្មានពាក់ព័ន្ធជាមួយសារណា ឬរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ចំពោះទិន្នន័យលទ្ធផលនៃការស្រាវជ្រាវដែលមានក្នុងរបាយការណ៍ស្រាវជ្រាវនេះ គឺថ្មីហើយក៏មិនទាន់មានជនណាម្នាក់យកទៅប្រើប្រាស់នៅក្នុងសារណា ឬរបាយការណ៍ស្រាវជ្រាវរបស់គេឡើយ។

ថ្ងៃ.................ខែ................ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ភ្នំពេញ ថ្ងៃទី..........ខែ............ឆ្នាំ២០....

**ហត្ថលេខា**

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

អាករបំភ្លឺសាធារណៈត្រូវបានបង្កើតឡើងដោយច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ គឺមាត្រា២៣។ ប៉ុន្តែមាត្រា២៣ នេះត្រូវបានប្តូរទៅជាមាត្រា២៣ថ្មី ដោយការធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ២០០២ ចំពោះតម្លៃស្រា ស្រាបៀរ និងបារី ដែលលក់នៅក្នុងដែនដីខេត្តក្រុង។ ដូចនេះមាត្រាទី២៣ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩ ត្រូវបានទុកនិរាករណ៍។ យើងសង្កេតឃើញមានប្រកាសអន្តរក្រសួងលេខ ១៧៥ សហវ.ពដ.ប្រក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ ២០២២ ស្តីពីការគ្រប់គ្រងនិងការប្រមូលអាករបំភ្លឺសាធារណៈ។ ប្រកាសនេះដើរតួនាទីយ៉ាងសំខាន់នៅក្នុងការធ្វើនិយ័តកម្មលើការអនុវត្ត និងការប្រមូលអាករបំភ្លឺសាធារណៈ Tax on public lighting។

បុគ្គលដែលធ្វើការផ្គត់ផ្គង់ ស្រា ស្រាបៀរ និងបារី គឺជាបុគ្គលជាប់អាករបំភ្លឺសាធារណៈ និងទទួលខុសត្រូវចំពោះអាករនេះ។ បុគ្គលជាប់អាករត្រូវប្រមូលយកអាករបំភ្លឺសាធារណៈ នេះពីអតិថិជនរបស់ខ្លួន និងយកប្រាក់អាករនេះបង់ជូន អគ្គនាយកដ្ឋានពន្ធដារ រឺសាខាពន្ធដារខេត្ត ខណ្ឌ ។

កាលពីមុនអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ធ្វើការបង់ប្រាក់ពន្ធ និងស្នើសុំទម្រង់លិខិតប្រកាសពន្ធ នៅតាមសាខាពន្ធដារខណ្ឌរៀងៗខ្លួន។ ប៉ុន្តែដោយមានភាពលំបាកពេកសម្រាប់មន្ត្រីពន្ធក៏ដូចជាអ្នកជាប់ពន្ធរាជរដ្ឋាភិបាលកម្ពុជាបានធ្វើកំណែទម្រង់មួយចំនួនដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយធ្វើការផ្លាស់ប្តូរនីតិវិធីក្នុងការប្រមូលពន្ធ-អាករ និងការដាក់លិខិតប្រកាសពន្ធផ្សេងឱ្យមានលក្ខណៈទំនើប និងងាយស្រួលសម្រាប់អ្នកជាប់ពន្ធនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

# មាតិកា


ទំព័រ

អារម្ភកថា ........ i

សេចក្តីថ្លែងអំណរគុណ ........ ii

អំណះអំណាង ........ iii

សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ iv

**ជំពូកទី១: សេចក្តីផ្តើម**

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ១

១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២

១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២

១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ២

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ២

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

**ជំពូកទី២: រំលឹកទ្រឹស្តី**

២.១ លក្ខណៈទូទៅនៃការប្រមូលអាករបំភ្លឺសាធារណៈ ........ ៤

២.១.១ និយមន័យអាករបំភ្លឺសាធារណៈ ........ ៤

២.១.២ ប្រវត្តិអាករបំភ្លឺសាធារណៈ ........ ៤

២.១.៣ ទំនិញដែលជាប់អាករបំភ្លឺសាធារណៈ ........ ៤

២.២ ការកំណត់ពន្ធនៃអាករបំភ្លឺសាធារណៈ ........ ៤

២.២.១ និយមន័យពន្ធ ........ ៤

២.២.២ ប្រវត្តិពន្ធ ........ ៥

២.២.៣ ប្រភេទពន្ធ ........ ៦

២.២.៤ ច្បាប់នឹងបទប្បញ្ញត្តិស្តីពីពន្ធដារពាក់ព័ន្ធការចុះបញ្ជីពន្ធដារ ........ ៦

២.៣ ការប្រមូលអាករបំភ្លឺសាធារណៈ ........ ០៩

២.៣.១ និយមន័យ ........ ០៩

២.៣.២ ប្រវត្តិនៃអាករ ........ ១០

២.៣.៣ ប្រភេទនៃអាករ ........ ១១

**ជំពូកទី៣: លទ្ធផលនៃការស្រាវជ្រាវ**

៣.១ ស្ថានភាពទូទៅនៃអគ្គនាយកដ្ឋានពន្ធដារ ........ ១៤

៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ ........ ១៤

៣.១.២ ចក្ខុវិស័យ បេសកកម្មពន្ធដាររបស់អគ្គនាយកដ្ឋានពន្ធដារ ............................ ១៦
៣.១.៣ ភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ.......................................................... ១៦
៣.១.៤ និមិត្តសញ្ញារបស់អគ្គនាយកដ្ឋានពន្ធដារ.....................................................១៧
៣.១.៥ រចនាសម្ព័ន្ធរបស់អគ្គនាយដ្ឋានពន្ធដារ.......................................................១៧
៣.២ ការកំណត់ពន្ធនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ ................ ១៩
៣.២.១ ការបង្កើតអាករបំភ្លឺសាធារណៈ................................................................ ១៩
៣.២.២ បុគ្គលជាប់អាករ ........................................................................................ ១៩
៣.២.៣ ទំនិញជាប់អាករ ........................................................................................២០
៣.៣ វិធីនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ................................ ២១
៣.៣.១ ការប្រមូលប្រាក់អាករ.................................................................................. ២១
៣.៣.២ នីតិវិធីក្នុងការទទួលលិខិតប្រកាស.............................................................. ២៣

## ជំពូកទី៤: ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង........................................................................................ ២៧
៤.២ ការវិភាគលើចំណុចខ្សោយ ..................................................................................... ២៧

## ជំពូកទី៥: សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន .................................................................................................. ២៩
៥.២ ការផ្តល់អនុសាសន៍ ............................................................................................... ៣០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាគឺជាប្រទេសដែលកំពុងមានការអភិវឌ្ឍន៍ដែលមានប្រជាជនប្រមាណប្រហែល១៧ លាននាក់គ្រប់គ្រងដោយរបបប្រជាធិបតេយ្យសេរីពហុបក្ស។ ជាមួយគ្នានេះផងដែរ ប្រទេសកម្ពុជាមានប្រភពចំណូលមកពីវិស័យជាច្រើន មានដូចជាវិស័យកសិកម្ម និងវិស័យទេសចរណ៍ ដែលវិស័យទាំងនេះជាវិស័យចម្បងក្នុងការលើកកម្ពស់សេដ្ឋកិច្ចឱ្យមានការរីកចម្រើន។ ជាមួយគ្នានេះផងដែរ ប្រទេសកម្ពុជាមានការរីកចម្រើនដូចពេលបច្ចុប្បន្នដោយសារមានគោលនយោបាយរូបិយវត្ថុ។

ជាក់ស្តែងគោលនយោបាយសារពើពន្ធ គឺជាគោលនយោបាយមួយប្រភេទដែលបង្កើតឡើង និងគ្រប់គ្រងដោយអគ្គនាយកដ្ឋានពន្ធដារ ក្នុងគោលបំណងតាមដានចំណូល ចំណាយ របស់រាជរដ្ឋាភិបាលតាមរយៈការប្រមូលពន្ធពីប្រជាពលរដ្ឋ សហគ្រាស ឬ ក្រុមហ៊ុនជាដើម។ ការប្រមូលពន្ធនេះ មានពន្ធលើប្រាក់ចំណូល ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ពន្ធអប្បរមា ពន្ធកាត់ទុក ពន្ធលើប្រាក់បៀវត្ស អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញ និងសេវាចំនួន ពន្ធលើផលរបរ ពន្ធឈ្នួលផ្ទះ ពន្ធតែមប្រ៊ី ពន្ធប៉ាតង់ ពន្ធប្រថាប់ត្រា ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ពន្ធលើមធ្យោបាយដឹកជញ្ជូន អាករស្នាក់នៅ អាករបំភ្លឺសាធារណៈ និងពន្ធអចលនទ្រព្យ។ ម្យ៉ាងវិញទៀតពន្ធដារក៏មានតួនាទីយ៉ាងសំខាន់ផងដែរ ក្នុងការរួមចំណែកបង្កើនថវិកាជាតិសម្រាប់ធានាឱ្យបាននូវសេចក្តីត្រូវការ និងចំណាយសាធារណៈដែលកាន់តែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំទៀត។ ប៉ុន្តែការគណនា និងការប្រមូលពន្ធគឺជាការងារស្មុគស្មាញ តែការប្រមូលចំណូលពន្ធមិនអាចប្រមូលបានដោយគ្រាន់តែមានច្បាប់ពន្ធដារតែប៉ុណ្ណោះទេ គឺអ្នកជាប់ពន្ធក៏ត្រូវចូលរួមចំណែកយល់ដឹង ពីសារៈសំខាន់ នៃពន្ធដារ ព្រមទាំងយល់ពីច្បាប់ពន្ធដារ ហើយរាយការណ៍ និងបង់ពន្ធជូនរដ្ឋដោយស្មោះត្រង់នោះទើបរដ្ឋអាចទទួលយកប្រាក់ចំណូលបានយ៉ាងពេញលេញ។

ដោយសារលើហេតុផលខាងលើនេះហើយ ទើបខ្ញុំបាទសម្រេចចិត្តជ្រើសរើសយកប្រធានបទស្តីពី **ដំណើរការ នៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ** យកមកស្រាវជ្រាវ និងចងក្រងជារបាយការណ៍បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។

## ១.២ ចំណោទបញ្ហា នៃការស្រាវជ្រាវ

ជាទូទៅប្រភេទពន្ធ និងអ្នកជាប់ពន្ធមានលក្ខណៈផ្សេងៗគ្នា ទៅតាមប្រភេទអាជីវកម្មនីមួយៗ ដែលធ្វើប្រតិបត្តិការ ហេតុដូច្នេះទើបខ្ញុំបាទមានសំនួរមួយចំនួនដូចខាងក្រោម៖

១.តើអគ្គនាយកដ្ឋានពន្ធដារ បានកំណត់ពន្ធនៃអាករបំភ្លឺសាធារណៈចាប់តាំងពីពេលណា?

២.តើអគ្គនាយកដ្ឋានពន្ធដារ ធ្វើការប្រមូលអាករបំភ្លឺសាធារណៈតាមវិធីណា ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះ គឺបង្ហាញពីយន្តការនៃការគណនាអាករបំភ្លឺសាធារណៈ និងអត្ថប្រយោជន៍បន្ថែម ឱ្យអ្នកដែលជាប់ពន្ធទាំងអស់ យល់ដឹងឱ្យបានច្បាស់ពីកាតព្វកិច្ចរបស់ខ្លួន ក្នុងការប្រកាសពន្ធ និងមិនបាត់បង់ចំណូលរបស់ថវិកាជាតិដែរ ដោយផ្តោតទៅលើ៖

- ប្រវត្តិនៃអគ្គនាយកដ្ឋានពន្ធដារកម្ពុជា
- គោលនយោបាយ បេសកកម្ម និងទស្សនវិស័យរបស់ពន្ធដារ
- រចនាសម្ព័ន្ធរបស់ពន្ធដារ
- តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ

## ១.៤ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំ និងដែលកំណត់

ការសិក្សាស្រាវជ្រាវនេះ គឺសិក្សាទៅលើ «ដំណើរការនៃការប្រមូលពន្ធអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ» នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ១.៤.២ វិសាលភាព

តាមច្បាប់ស្តីពីសារពើពន្ធ ពន្ធត្រូវបានបង្កើតឡើងយូរណាស់មកហើយ ហើយដោយមានពេលវេលាកំណត់ ការសិក្សាស្រាវជ្រាវ និងស្វែងយល់អំពី ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ ទើបខ្ញុំបាទធ្វើការស្រាវជ្រាវតែក្នុងឆ្នាំ ២០២២ តែប៉ុណ្ណោះ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីឱ្យដំណើរការនៃការសរសេរបាយការណ៍លើប្រធានបទ **«ដំណើរការនៃការប្រមូលពន្ធអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ»** ឱ្យបានជោគជ័យ ខ្ញុំបាទបានធ្វើការស្រាវជ្រាវដូចខាងក្រោម៖

### ១.៥.១ ការប្រមូលទិន្នន័យដំបូង

ការប្រមូលទិន្នន័យដំបូង គឺជាការប្រមូលទិន្នន័យតាមរយៈការចុះសួរដោយផ្ទាល់ពីមន្ត្រី និងអ្នកគ្រប់គ្រង នៃអគ្គនាយកដ្ឋានពន្ធដារ។ ដោយឯកសារដែលខ្ញុំប្រមូលបានត្រូវរៀបចំតាមលំដាប់លំដោយជាផ្នែកៗទៅតាមខ្លឹមសារអត្ថន័យនៃឯកសារនីមួយៗដោយឡែកពីគ្នា ដើម្បីងាយស្រួលក្នុងការសរសេរបាយការណ៍ស្រាវជ្រាវឱ្យកាន់តែងាយស្រួល និងប្រសើរឡើង។

### ១.៥.២ ការប្រមូលទិន្នន័យបន្ទាប់

ការប្រមូលទិន្នន័យបន្ទាប់ គឺការប្រមូលទិន្នន័យតាមរយៈឯកសារដែលខ្ញុំធ្លាប់បានសិក្សានៅសាលាជាតិពន្ធ និងការស្រាវជ្រាវនៅបណ្ណាល័យនានា និងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ គឺជាការនាំមកនៅភាពរីកចម្រើនដល់និស្សិតជាច្រើន ក្នុងការប្តូរពួកគេឱ្យយល់ដឹងពីសកម្មភាពក្នុងសង្គម ការទំនាក់ទំនង និងប្រតិបត្តិការមួយចំនួននៅក្នុងពេលបច្ចុប្បន្ននេះ។

សារៈសំខាន់នៃការស្រាវជ្រាវនេះ គឺបានផ្តល់ចំណេះដឹងលើខ្ញុំបាទដូចជា៖

- មានការទំនាក់ទំនងគ្នា និងការចូលរួមក្នុងសង្គម
- មានបទពិសោធន៍ក្នុងការបង្ហាត់បង្រៀនក្នុងការដោះស្រាយបញ្ហានានា
- បង្កើតចំណេះដឹងបន្ថែម ទៅការសិក្សាស្រាវជ្រាវក៏ដូចជាការសិក្សា
- ធ្វើឱ្យនិស្សិតជាច្រើនមើលឃើញពីគុណតម្លៃ នៃការសិក្សាស្រាវជ្រាវផ្សេងៗ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធ នៃការស្រាវជ្រាវធ្វើឡើងដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ នៅចំណុចនីមួយៗនិងបានធ្វើឡើងដោយធ្វើការរាប់បញ្ចូលចំណុចដែលមានសេចក្តីផ្តើមនៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ សេចក្តីសន្និដ្ឋាន និងអនុសាសន៍ និងមានចំណុចជាច្រើនទៀត។ ក្រោយពីបានសិក្សាស្រាវជ្រាវរួចមកខ្ញុំក៏បានចែកជា ៥ ជំពូកដែលរៀបរាប់ដូចខាងក្រោម៖

ជំពូកទី១ សេចក្តីផ្តើម ៖ បរិយាយសង្ខេបពីលំនាំបញ្ហា គោលបំណង មូលហេតុនៃការស្រាវជ្រាវ ចំណោទបញ្ហា ដែនកំណត់ និងវិសាលភាព ហេតុផលមួយចំនួនដែលបង្កើតឱ្យមាន ការសិក្សាស្រាវជ្រាវ។

ជំពូកទី២ រំលឹកទ្រឹស្តី ៖ បង្ហាញពីនិយមន័យ ប្រវត្តិទូទៅពាក់ព័ន្ធ និងទ្រឹស្តីរបស់អ្នកប្រាជ្ញ ដែលពាក់ព័ន្ធនិងការសិក្សាស្រាវជ្រាវ។

ជំពូកទី៣ លទ្ធផលនៃការស្រាវជ្រាវ ៖ បង្ហាញពីស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ គោលនយោបាយ ទស្សនៈវិស័យ និងបេសកកម្ម គោលដៅ របស់អគ្គនាយកដ្ឋានពន្ធដារ។

ជំពូកទី៤ ការវិភាគពីចំណុចខ្លាំង និងចំណុចខ្សោយ៖ វិភាគនិងធ្វើការស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ។

ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ ៖ សន្និដ្ឋានទៅលើចំណុចទាំងអស់ ដែលនៅក្នុងអត្ថបទ និងផ្តល់អនុសាសន៍ទៅលើចំណុចដែលមានកង្វះខាតដើម្បីកែលម្អ។

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូកទី២

# ការប្រមូលអាករបំភ្លឺសាធារណៈ

## ២.១ លក្ខណៈទូទៅនៃការប្រមូលអាករបំភ្លឺសាធារណៈ

### ២.១.១ និយមន័យអាករបំភ្លឺសាធារណៈ

អាករបំភ្លឺសាធារណៈ (public light tax) គឺជាប្រភេទពន្ធប្រយោលដែលអ្នកប្រើប្រាស់មានកាតព្វកិច្ចត្រូវបង់ ហើយដែលត្រូវប្រមូលដោយអ្នកលក់ដើម្បីបង់ជូនរដ្ឋ[1]។

អាករបំភ្លឺសាធារណៈ (public light tax) គឺជាប្រភេទពន្ធប្រយោលដែលគិតទៅលើតម្លៃ ស្រា ស្របៀ និងបារី ដែលអ្នកប្រើប្រាស់មានកាតព្វកិច្ចត្រូវបង់ ហើយដែលត្រូវកាត់ទុកដោយអ្នកលក់ ដើម្បីបង់ជូនរដ្ឋជាបន្តនាពេលក្រោយទៀត[2]។

អាករបំភ្លឺសាធារណៈ (public light tax) គឺជាអាករមួយប្រភេទដែលត្រូវកំណត់លើគ្រប់ដំណាក់កាល នៃការផ្គត់ផ្គង់ សុរាមេរ័យ (គ្រឿងស្រវឹង) និងបារី ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជាប្រយោជន៍ដល់ថវិកាថ្នាក់ក្រោមជាតិសម្រាប់បំភ្លឺសាធារណៈ នៅព្រះរាជាណាចក្រកម្ពុជា[3]។

### ២.១.២ ប្រវត្តិអាករបំភ្លឺសាធារណៈ

អាករបំភ្លឺសាធារណៈត្រូវបានបង្កើតឡើងដោយច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩ គឺមាត្រា២៣។

### ២.១.៣ ប្រភេទទំនិញដែលត្រូវជាប់អាករបំភ្លឺសាធារណៈ

អាករបំភ្លឺសាធារណៈ (public light tax) ត្រូវបានកំណត់តាមអាត្រា **៣%** នៅពេលនាំចូល និងលក់ចេញពីរោងចក្រ និងសំរាប់អាត្រា **(២០%*៣%)** គឺសំរាប់ដេប៉ូដែលចែកចាយលក់បន្តពីរោងចក្រ។

អាករបំភ្លឺសាធារណៈត្រូវបានកំណត់តាមអាត្រា **៣%**លើការផ្គត់ផ្គង់ទំនិញចេញពីរោងចក្រ និងការនាំចូលគ្រប់ដំណាក់កាលនូវ **ស្រា ស្រាបៀរ និងបារី**។ អ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់ផលិតផលទាំងនេះត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់អាករនេះ ជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ២០ នៃខែបន្ទាប់ និងត្រឹមថ្ងៃទី ២៥ តាមប្រពន្ធ័ E-Filling។

## ២.២ ការកំណត់ពន្ធនៃអាករបំភ្លឺសាធារណៈ

### ២.២.១ និយមន័យពន្ធ

**ពន្ធ** គឺជាបន្ទុករបស់អ្នកជាប់ពន្ធចំពោះរដ្ឋ និងជាកាតព្វកិច្ចរបស់គ្រប់សមាសភាពដែលកំណត់ដោយច្បាប់។ យោងតាមច្បាប់ស្តីពីពន្ធដារឆ្នាំ ១៩៩៩ ពន្ធនេះសំដៅដល់ពន្ធផ្ទាល់ ដែលជាប្រភេទពន្ធប្រមូលយកដោយផ្ទាល់ពីអ្នកជាប់ពន្ធ (Taxpayer) ក្រៅពីពន្ធគយ ឬអាករដែលសំដៅដល់ពន្ធប្រយោលដែលជាប្រភេទនៃការប្រមូលពន្ធ ដោយប្រយោល ( **មិនបានប្រមូលយកដោយផ្ទាល់ពីអ្នកជាប់ពន្ធ**)។ ការប្រមូលពន្ធនេះ គឺជាការយកតាមតម្លៃ ទំនិញ និងសេវា ពីអ្នកជាប់ពន្ធប្រើប្រាស់ចុងក្រោយ។

**ពន្ធ** គឺជាកាតព្វកិច្ចបង់ជាប្រាក់ ឬវត្ថុរបស់អ្នកជាប់ពន្ធទៅរដ្ឋាភិបាលហើយអ្នកជាប់ពន្ធទាំងនោះទទួលតម្លៃតបស្នងពីរដ្ឋាភិបាលវិញតាមរយៈទំនិញ និងសេវាសាធារណៈ។

---

[1] សាលាជាតិពន្ធដារ៖ វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈពន្ធដារជំនាន់ ១៧ មេរៀនអាករបំភ្លឺសាធារណៈ ទំព័រលេខ ៥៤

[2] www.tax.gov.kh (10 12 2023)

[3] https://web.facebook.com/ReanAccounting/ (10 12 2023)

ពន្ធ គឺជាបន្ទុករបស់ប្រជាពលរដ្ឋបង់ចូលថវិកាជាតិ។ ប្រជាពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចបង់ជូនរដ្ឋ។

ពន្ធ ជាឧបករណ៍របស់រដ្ឋាភិបាល ដែលបានបង្កើតឡើង ដើម្បីប្រមូលចំណូលចូលថវិកាជាតិសម្រាប់ចំណាយសេវាសាធារណៈ។

ពន្ធ សំដៅ ពន្ធអាករ (ពន្ធផ្ទាល់ និងពន្ធប្រយោល)

ពន្ធ មានលក្ខណៈបង្ខំហើយមិនសងឱ្យវិញផ្ទាល់ឡើយ ប៉ុន្តែនិងអាចសងឱ្យវិញជាលក្ខណៈរូបភាពប្រយោលទៅតាមគោលដៅនយោបាយប្រទេសនីមួយៗ។ គ្រប់អង្គភាពអាជីវកម្ម សេវាកម្មដែលចំណុះឱ្យគ្រប់សមាសភាពសេដ្ឋកិច្ចត្រូវមានកាតព្វកិច្ចនិងទំនួលខុសត្រូវ ចំពោះមុខច្បាប់ក្នុងការអនុវត្តន៍ឱ្យបានគ្រប់គ្រាន់ក្នុងខ្ទង់ពន្ធទាំងឡាយដែលបានកំណត់ និងមានសិទ្ធិស្មើៗគ្នាក្នុងការទទួលមកវិញនូវផលប្រយោជន៍ពីរដ្ឋាភិបាលដែលប្រកបដោយយុត្តិធម៌ព្រមទាំងមានភាពងាយស្រួល។

ពន្ធ បានធ្វើឱ្យមានការផ្លាស់ប្តូរកម្មសិទ្ធិនៃប្រភពចំណូលដែលបានប្រមូល។ ការផ្លាស់ប្តូរកម្មសិទ្ធិនៃប្រភពចំណូលនេះបានកំណត់ដោយមុខងារគ្រប់គ្រងសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ហើយបានស្តែងឡើងនៅការឯកភាពគ្នាអំពីគោលចរិតផលប្រយោជន៍របស់រដ្ឋជាមួយនិងផលប្រយោជន៍របស់ក្រុមហ៊ុនសេវាកម្ម និងប្រជាជនគ្រប់រូប។ នៅក្នុងយឿនសេដ្ឋកិច្ចទីផ្សារ ដែលមានសមាសភាពសេដ្ឋកិច្ចច្រើនគោលនយោបាយពន្ធដារត្រូវយកមកប្រើប្រាស់ជាចាំបាច់ ជាទូទៅពន្ធដារបានចាត់ជាឧបករណ៍ហិរញ្ញវត្ថុយ៉ាងមានប្រសិទ្ធភាព នៅក្នុងការគ្រប់គ្រងសេដ្ឋកិច្ចហិរញ្ញវត្ថុរបស់រដ្ឋាភិបាលដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសជាតិ[4]។

**២.២.២ ប្រវត្តិពន្ធ**

ប្រព័ន្ធពន្ធដារត្រូវបានបង្កើតឡើងដំបូងនៅឆ្នាំ**១៩៥៣** ហើយត្រូវបានលុបចោលនៅឆ្នាំ**១៩៧៥-១៩៧៩** ដោយសារមានការកើតឡើងនៅរបបប្រល័យពូជសាសន៍របប (ប៉ុល ពត) និងបានធ្វើឱ្យប្រជាជនជួបការលំបាក និងរហូតដល់បាត់បង់ជីវិត។ ប្រព័ន្ធពន្ធដារត្រូវបានបង្កើតឡើងវិញនៅឆ្នាំ ៖

**១៩៨០-១៩៩៣** ដែលត្រូវបានហៅថាជា នាយកដ្ឋានពន្ធដារឧស្សាហាពាណិជ្ជក្រសួងហិរញ្ញវត្ថុ

**១៩៩៣-២០០៨** ដែលត្រូវបានហៅថាជា នាយកដ្ឋានពន្ធដារ (អង្គភាពពន្ធដារ)

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**២០០៨** ត្រូវបានដំឡើងជាអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

លើសពីនេះទៅទៀតអគ្គនាយកដ្ឋានពន្ធដារបានបង្កើតពន្ធមួយចំនួនផ្សេងទៀតដើម្បីយកអនុវត្ត និងមានការបែងចែកច្បាប់ និងមាត្រាយ៉ាងច្បាស់លាស់។ ផ្អែកទៅលើមាត្រា៤ នៃច្បាប់សារពន្ធបានបង្កើតឡើងនូវការកំណត់របបពន្ធជាបីប្រភេទ៖ គឺរបបពិត របបម៉ៅការ របបបំព្រួញ ក៏ប៉ុន្តែបទប្បញ្ញត្តិស្តីពីរបបបំព្រួញមានចែងក្នុងក្រជាសមួយដាច់ដោយឡែក។ ដែលជាវិធាន និងជានីតិវិធីដើម្បីចាត់បញ្ចូនអ្នកជាប់ពន្ធឱ្យស្ថិតនៅក្នុរបបកំណត់ណាមួយនោះ ត្រូវកំណត់ដោយផ្អែកទៅលើទ្រង់ទ្រាយអាជីវកម្ម និងកម្រិតផលរបរ។ ប៉ុន្តែនៅពេលបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជាយើងមានតែរបបពិត(ស្វ័យប្រកាស)តែប៉ុណ្ណោះ។

ការអនុវត្តន៍ និងការកំណត់នៃរបបពិតរបស់សហគ្រាសដោយផ្អែកទៅលើទ្រង់ទ្រាយគតិយុត្តិនៃកម្រិតផលរបរប្រចាំឆ្នាំ និងប្រភេទសកម្មភាពអាជីវកម្ម។

[4] សាលាជាតិពន្ធដារ៖ វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈពន្ធដារជំនាន់ ១៧ មេរៀនសេចក្តីផ្តើមនៃការប្រមូលពន្ធ ទំព័រទី ៤

ទ្រង់ទ្រាយគតិយុត្តិមានន័យថា រាល់សហគ្រាសដែលមិនមែនជាសហគ្រាសឯកបុគ្គល គឺត្រូវជាប់ពន្ធ របបពិត ទោះបីសហគ្រាសនោះមានអាជីវកម្មប្រភេទអ្វី ឬមានកម្រិតផលរបរប្រចាំឆ្នាំប៉ុន្មានក៏ដោយ។ សហគ្រាសទាំងនោះមានដូចជាសហគ្រាសចម្រុះ ក្រុមហ៊ុនឯកជន សមូហភាពសាធារណៈ ឬអង្គការឯកជន ដែលធ្វើសកម្មភាពក្នុងលក្ខខណ្ឌប្រាក់ចំណូលដែលជាបេតិកភណ្ឌរបស់ខ្លួន។

កម្រិតផលរបរប្រចាំឆ្នាំគឺជាការកំណត់ពន្ធលើប្រាក់ចំណូលតាមរបបពិតដែលត្រូវអនុវត្តហើយចំពោះសហគ្រាសដែលមានផលរបរប្រចាំឆ្នាំចាប់ពី ៥០០លានរៀលឡើងទៅ។ ចំណែកឯការផ្គត់ផ្គង់ចម្រុះដែលមានរបរប្រចាំឆ្នាំចាប់ពី ២៥០លានរៀលឡើងទៅ។

រាល់សហគ្រាសដែលធ្វើការដេញថ្លៃ ប្រសិនបើសហគ្រាសទាំងនោះបានទទួលសញ្ញាធ្វើ ឬក៏ជាការផ្គត់ផ្គង់របស់អង្គការសាធារណៈដែលមានចំនួនទឹកប្រាក់ប្រចាំឆ្នាំសរុប ១២៥លានរៀល សកម្មភាពសេវាកម្ម ដូចជា សណ្ឋាគារ កន្លែងម៉ាស្សា រង្គសាល ភោជនីយដ្ឋាន កន្លែងកម្សាន្តនានាដែលចាត់ថ្នាក់ជាគ្រឹះស្ថានធើតសកម្មភាពអណ្តូងរ៉ែ និងអាជីវកម្មនេសាទ។

ដើម្បីថែរក្សាផលប្រយោជន៍សាធារណៈទាំងអស់ ចាំបាច់ត្រូវឱ្យមានការចូលរួមពីសំណាក់មហាជន។ តាមការស្រាវជ្រាវ ការកកើតពន្ធ ឬទ្រឹស្តីទាក់ទងនឹងពន្ធត្រូវបានគេរកឃើញថា បានកើតឡើងស្របជាមួយនឹងការកកើតឡើងនៃការប្រមូលផ្តុំគ្រប់គ្រងដំបូង និងនៅពេលដែលមានការកើតចេញឡើង នូវទម្រង់អង្គការចាត់តាំងនៃសង្គមមនុស្ស។ Evolution នៃសង្គមមនុស្សជាហេតុផលដែលបង្ហាញពីភាពងាយស្រួលនៃការប្រមូលពន្ធដែលស្ថិតនៅលើរបត់មួយដ៏យូរលង់ត្រូវបានឆ្លោះមករកភាពសាំញ៉ាំ និងពិបាកមកដល់បច្ចុប្បន្ននេះ។

**២.២.៣ ប្រភេទពន្ធ**

ពន្ធ គឺជាចំណូលចរន្តដ៏សំខាន់របស់រដ្ឋ សម្រាប់ធ្វើការទ្រទ្រង់នូវដំណើរការវិស័យសាធារណៈផ្សេងៗ។ នៅកម្ពុជាបច្ចុប្បន្នបានកំណត់នូវពន្ធចំនួន ១៨ប្រភេទ ដែលតម្រូវឱ្យប្រជាពលរដ្ឋ ឬអ្នកជាប់ពន្ធទាំងអស់ត្រូវធ្វើការបង់ជូនរដ្ឋ។ ប្រភេទពន្ធទាំងនោះរួមមាន៖

- ពន្ធលើប្រាក់ចំណេញ
- ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ
- ពន្ធអប្បបរមា
- ពន្ធកាត់ទុក
- ពន្ធលើប្រាក់បៀវត្ស
- អាករលើតម្លៃបន្ថែម
- អាករលើផលរបរ
- ពន្ធលើឈ្នួលផ្ទះ និងដី
- អាករពិសេសលើទំនិញ និងសេវាមួយចំនួន
- ពន្ធតែមប្រ៊ី
- ពន្ធប៉ាតង់
- ពន្ធប្រថាប់ត្រា
- ពន្ធលើដីធ្លីមិនបានប្រើប្រាស់

- ពន្ធសត្តឃាត
- អាករស្នាក់នៅ
- អាករបំភ្លឺសាធារណៈ
- ពន្ធលើអចលនទ្រព្យ
- ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ[5]។

**២.២.៤ ច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារពាក់ព័ន្ធការចុះបញ្ជីពន្ធដារ**

មាត្រាទី១០១ នៃច្បាប់ស្តីពីសារពើពន្ធ

«បុគ្គលទាំងឡាយត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងកំឡុង១៥ថ្ងៃ ក្រោយពីបុគ្គលនេះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច»។ «ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានក្នុងកំឡុង១៥ថ្ងៃ ក្រោយពីផ្លាស់ប្តូរឈ្មោះអាស័យដ្ឋានទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម ការផ្ទេរ ការបញ្ឈប់អាជីវកម្ម សមាសភាពអ្នកគ្រប់គ្រង ឬអ្នកទទួលបន្ទុកកិច្ចការពន្ធដារបស់សហគ្រាស»។

មាត្រា៣(ថ្មី)នៃច្បាប់ស្តីពីសារពើពន្ធ

«**នីតិបុគ្គល**» សំដៅដល់សហគ្រាស ឬអង្គភាពនានាដែលប្រកបអាជីវកម្ម ទោះបីបាន ឬមិនទាន់បានទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលក្តី។ ពាក្យ«**នីតិបុគ្គល**»រួមបញ្ចូលផងដែរនូវស្ថាប័នរដ្ឋាភិបាល អង្គការ សាសនា អង្គការសប្បុរសធម៌ ឬអង្គការមិនស្វែងរកប្រាក់ចំណេញ។ ចំពោះបុគ្គលអនិវាសនជន ពាក្យ«**នីតិបុគ្គល**»សំដៅដល់គ្រឹះស្ថានអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជា។ ពាក្យ«**នីតិបុគ្គល**»ពុំរាប់បញ្ចូលទេនូវក្រុមហ៊ុនអាជីវកម្ម ឬសហគ្រាសឯកបុគ្គល។

**ប្រកាសលេខ ៤៩៦ សហវ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការចុះបញ្ជីពន្ធដារ**

«**សកម្មភាពសេដ្ឋកិច្ច**» សំដៅដល់សកម្មភាពរបស់បុគ្គលដែលធ្វើជានិច្ចជាការជាប់បន្ត ឬមួយដងមួយគ្រាដើម្បីរក ឬមិនរកប្រាក់ចំណេញ ក្នុងការផ្គត់ផ្គង់ ឬមានបំណងផ្គត់ផ្គង់ទំនិញ ឬសេវាកម្មឱ្យដល់បុគ្គលដទៃ ក្នុងគោលដៅដើម្បីបានអត្ថប្រយោជន៍អ្វីមួយ។

«**អាជីវកម្ម**» សំដៅដល់សកម្មភាពរបស់បុគ្គលដែលមានគោលដៅ ទាញយកប្រាក់ចំណូលពីការផលិតនិងលក់ទំនិញ ការផ្គត់ផ្គង់សេវា ភតិសន្យា ការជួល ឬការលក់ទ្រព្យសម្បត្តិ ឬសកម្មភាពផ្សេងៗទៀត។

**ប្រកាសលេខ០២៥ សហវ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែប្រែប្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស**

**អ្នកជាប់ពន្ធតូច** គឺជាសហគ្រាសឯកបុគ្គល មានផលរបរប្រចាំឆ្នាំចាប់ពី ២៥០លានរៀល ដល់ ១០០០ លានរៀល (62500$ - 250000$) ឬមានផលរបរ ឬរំពឹងថាផលរបរក្នុងរយៈពេលបីខែជាប់គ្នាណាមួយ ដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តចាប់ពី៦០លាន (ប្រមាណ 15,000$)ឡើងទៅ។

[5] https://www.tax.gov.kh (15 12 2023)

**អ្នកជាប់ពន្ធមធ្យម** គឺជាសហគ្រាសមានផលរបរប្រចាំឆ្នាំលើសពី ១០០០លានរៀល ដល់៤,០០០លានរៀល (250,000$ - 1,000,000$)។

**អ្នកជាប់ពន្ធធំ** គឺជាសហគ្រាសមានផលរបរប្រចាំឆ្នាំលើសពី ៤,០០០លានរៀល (1,000,000$) ឡើងទៅ។ ក្នុងការចុះបញ្ជីពន្ធដារចំពោះសកម្មភាពដោយឡែកសំណុំឯកសារភ្ជាប់ទាំងអស់ដែលជាច្បាប់ថតចម្លង ដែលតម្រូវឱ្យភ្ជាប់សម្រាប់ចុះបញ្ជីពន្ធដារត្រូវមានការបញ្ជាក់ «**ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**»ពីមន្ត្រីពន្ធដារ មានសមត្ថកិច្ច ឬក្រសួងពាក់ព័ន្ធ។

➢ **សម្រាប់អ្នកជាប់ពន្ធតូច**

| ឯកសារតម្រូវ | |
|---|---|
| ១ | បំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារ (ទម្រង់ SOI) |
| ២ | អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព |
| ៣ | រូបថតបច្ចុប្បន្នមិនលើសពី ០៣ខែ ទំហំ ៣៤ x ៤៥ មីលីម៉ែត្រ ផ្ទៃខាងក្រោយពណ៌ស ចំនួន ២សន្លឹក ដែលមានបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវដោយប្រធាន ឬតំណាងសមាគម ឬអង្គភាពនានា |
| ៤ | បណ្ណកម្មសិទ្ធកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងអាជីវកម្ម |
| ឯកសារត្រូវភ្ជាប់បើមាន | |
| ១ | លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ |
| ២ | លិខិតបញ្ជាក់ការបង់ពន្ធលើអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ |
| ៣ | អាជ្ញាបណ្ណដែលចេញដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ច |

➢ **សម្រាប់អ្នកជាប់ពន្ធមធ្យម-ធំ**

| | |
|---|---|
| ១ | បំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារ (ទម្រង់១០១) |
| ២ | អត្តសញ្ញាណប័ណ្ណ ឬលិខិតបញ្ជាក់ការចុះបញ្ជី ចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ |
| ៣ | លក្ខន្តិកៈរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល |
| ៤ | ព័ត៌មានគណនីធនាគារសម្រាប់សកម្មភាពអាជីវកម្មដោយឡែក ដូចជាលិខិតបញ្ជាក់គណនីធនាគារ របាយការណ៍ធនាគារ ឬសៀវភៅធនាគារ ដែរចេញដោយធនាគារ |
| ៥ | អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន ដែលមានសុពលភាព |
| ៦ | រូបថតបច្ចុប្បន្នមិនលើសពី ០៣ខែ ទំហំ៣៥ x ៤៥ មីលីម៉ែត្រ ផ្ទៃខាងក្រោយពណ៌ស ចំនួន០២សន្លឹក ដែលមានបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវដោយប្រធាន ឬតំណាងសមាគម ឬអង្គភាពនានា |
| ៧ | លិខិតបញ្ជាក់ការបង់ពន្ធលើអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ |
| ៨ | អាជ្ញាបណ្ណដែលចេញដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ច |

បំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារ និងការដាក់ពាក្យស្នើសុំនៅរដ្ឋបាលសារពើពន្ធ

ទម្រង់101 (អ្នកជាប់ពន្ធមធ្យម-ធំ) ទម្រង់S01 (អ្នកជាប់ពន្ធតូច)





CS Scanned with CamScanner

**ទម្រង់អតប១០១** គឺជាពាក្យស្នើសុំចុះបញ្ជីសម្រាប់បុគ្គលជាប់អាករ ហើយក៏អាចប្រើជាពាក្យស្នើសុំចុះបញ្ជី ដោយស្ម័គ្រចិត្តផងដែរ។ ទម្រង់នេះត្រូវបានផ្តល់ជូនលោក/លោកស្រីដោយនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ។ លោក/លោកស្រីត្រូវបំពេញទម្រង់នេះ និងផ្តល់នូវព័ត៌មានបន្ថែមនានាទៅតាមការតម្រូវ ហើយយកទម្រង់នេះទៅដាក់ជូន នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់ពីខែដែលផលរបររបស់លោក/លោកស្រីមានការកើនឡើងលើសពីកម្រិតអប្បបរមា នៃផលរបរត្រូវចុះបញ្ជី។

ចំពោះក្រុមហ៊ុនដើមទុនគ្រប់ប្រភេទអ្នកនាំចេញនាំចូលសហគ្រាសវិនិយោគ ឬអង្គការរបស់រដ្ឋត្រូវបំពេញទម្រង់ហើយយកទៅ ដាក់ជូននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំទៅមុនពេលចាប់ផ្តើមប្រកបអាជីវកម្ម។ ចំពោះការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីលោក/លោកស្រីនឹងត្រូវទទួលរងទោសទណ្ឌទៅតាមច្បាប់ស្តីពីសារពើពន្ធ។ នៅពេលដាក់ពាក្យស្នើសុំចុះបញ្ជី អគ្គនាយកដ្ឋានពន្ធដារនឹងផ្តល់ជូនលោក/លោកស្រីនូវលេខចុះបញ្ជីដែលជាលេខ អត្តសញ្ញាណកម្មអតបរបស់លោក/លោកស្រី។ វិញ្ញាបនបត្រចុះបញ្ជីត្រូវបានផ្តល់ជូនលោក/លោកស្រី ហើយត្រូវតាំង ឬព្យួរវិញ្ញាបនបត្រនេះនៅទីកន្លែងអាជីវកម្ម ជាសំខាន់របស់ខ្លួន។ ប្រសិនបើការដាក់ពាក្យស្នើសុំចុះបញ្ជីត្រូវបានបដិសេធ អគ្គនាយកដ្ឋានពន្ធដារនឹងជូនដំណឹងដល់ លោក/លោកស្រីដោយភ្ជាប់ជាមួយនូវសេចក្តីពន្យល់ផ្សេងៗដែលជាហេតុផលនៃការបដិសេធ។

## ២.៣ ការប្រមូលអាករបំភ្លឺសាធារណៈ

### ២.៣.១ និយមន័យអាករ

អាករ គឺសំដៅដល់កាតព្វកិច្ចរបស់ប្រជាពលរដ្ឋ និងគ្រប់សមាសភាពសេដ្ឋកិច្ចត្រូវបង់ (សាច់ប្រាក់ ឬវត្ថុ) ជូនរដ្ឋតាមច្បាប់កំណត់ ដោយប្រយោល ហើយពន្ធនេះត្រូវប្រមូលពីអ្នកប្រើប្រាស់ចុងក្រោយតាមរយៈអ្នកផ្គត់ផ្គង់[6]។

[6] https://www.tax.gov.kh (13 01 2024)

និយាយឱ្យងាយយល់ អាករ មានន័យថាជាពន្ធប្រយោល ឬបន្ទុកប្រយោល ឬកាតព្វកិច្ចប្រយោល ដែលតម្រូវឱ្យបង់ដោយប្រយោលពីអ្នកជាប់ពន្ធ។

អាករ-ករ ឬ ក សំ. បា. (ន.) គំនរ; ពួក, ក្រុម; លោហធាតុផ្សេងៗ; កំណើតលោហធាតុ ឬកំណើតត្បូងផ្សេងៗ; ត្បូង ឬ លោហធាតុផ្សេងៗ; រ៉ែ; កំណាត់ទ្រព្យ។ គុ. ល្អលើសលន់, ល្អកន្លង។ ខ្មែរប្រើពាក្យនេះសំដៅសេចក្ដីថា "សួយ, តង្វាយ, ជំនូន; ប្រាក់ពន្ធ" : សួយអាករ ឬ សួយសារអាករ (ម. ព. សួយ)។ ទេយ្យទានដែលបុព្វជិតបានមកហៅ អាករ ដែល : ពីម្សិលមិញ លោកគ្រូខ្ញុំនិមន្តទៅទេសនាបានអាករសន្ធឹក។ (ខ្មែរសម័យបុរាណ លុះតែសួយឬពន្ធដែលហូតយកអំពីពួកអ្នកជីកររបរក្នុងដី មានអ្នកជីករកត្បូងជាដើម ឬ ទ្រព្យដែលបានអំពីគាស់កំណាត់ ឬក៏ត្បូង និងលោហៈធាតុដែលត្រូវហូតយកពីអ្នកទាំងនេះ, បើពុំនោះដែលគេថ្វាយជារាជបណ្ណាការទោះទើបហៅថា អាករ)។ បើរៀងភ្ជាប់ពីខាងដើមសព្ទដទៃ អ. ថ. អាកៈរៈ ដូចជា អាករកួប អណ្ដូងត្បូង, អណ្ដូងលោហៈធាតុ។ អាករដ្ឋាន ឬ --ស្ថាន ទីដែលមានត្បូង ឬ មានលោហៈធាតុ។ អាករខនិក ឬ អាករាខនិក (--ខៈ--) អ្នកជីករកត្បូង (បើស្រ្តីជា --ខនិកា)។ អាករវិទ ឬ --វិទូ អ្នកស្គាល់ត្បូង ឬអ្នកស្គាល់កន្លែងកើតត្បូង ។ល[7]។

### ២.៣.២ ប្រវត្តិនៃអាករ

អាករបំភ្លឺសាធារណៈត្រូវបានបង្កើតឡើងដោយច្បាប់ ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩ គឺមាត្រា២៣។

អាករលើតម្លៃបន្ថែម ដែលអតិថិជនបានទូទាត់តាមរយៈការទិញ ប្រើប្រាស់ ឬទូទាត់លើថ្លៃសេវាកម្ម ឬផលិតផលនានាគឺជាកាតព្វកិច្ចរបស់ ក្រុមហ៊ុន សហគ្រាស អាជីវកម្មនានាដែលចុះបញ្ជីស្របច្បាប់ត្រូវបង់ជូនរដ្ឋជំនួសអតិថិជន។

អាករលើតម្លៃបន្ថែមនេះ ជាប្រភេទពន្ធប្រយោលមួយ ដែលកំណត់ទៅលើការចំណាយទិញរបស់អ្នកប្រើប្រាស់ ដោយត្រូវប្រមូលពីការប្រកបអាជីវកម្ម និងការនាំចូល ទាក់ទិននឹងការផ្គត់ផ្គង់ទំនិញ ឬសេវាកម្មនានា។ អាករលើតម្លៃបន្ថែមនេះ ត្រូវបានរាជរដ្ឋាភិបាលចាប់ផ្ដើមអនុវត្តពីខែមករា ឆ្នាំ១៩៩៩ តរៀងមកដោយផ្ដល់នូវភាពអព្យាក្រិតដល់អ្នកជាប់ពន្ធ។

អាករលើផលរបរ គឺជាប្រភេទពន្ធប្រយោល ដែលត្រូវបានយកពន្ធពីសកម្មភាពសេដ្ឋកិច្ចផ្សេងៗដូចជា ពាណិជ្ជកម្ម ផលិតកម្ម អាជីវកម្ម និងសេវាកម្ម។ អាករលើផលរបរប្រមូលពីអ្នកប្រើប្រាស់ និងបង់ជូនរដ្ឋដោយអ្នកលក់។

អាករលើការស្នាក់នៅ គឺជាប្រភេទពន្ធប្រយោលដែលគិតលើតម្លៃសរុបនៃការជួលកន្លែងស្នាក់នៅដែលអ្នកប្រើប្រាស់សេវាស្នាក់នៅជាប់កាតព្វកិច្ចត្រូវបង់ និងដែលទទួលកាត់ទុកដោយអ្នកផ្គត់ផ្គង់ ដើម្បីបង់ជូនរដ្ឋជាបន្តបន្ទាប់នាពេលក្រោយទៀត។

អាករលើការស្នាក់នៅ(Accommodation Tax)គឺត្រូវបានកំណត់ និងប្រមូលលើការស្នាក់នៅក្នុងសណ្ឋាគារដែលជាប់ពន្ធក្នុងរបបស្វ័យប្រកាស សម្រាប់ជាគុណប្រយោជន៍ថវិកាថ្នាក់ក្រោមជាតិ លើកលែងតែសកម្មជាការប្រជុំឬសិក្ខាសាលាជាដើម។

[7] វិទ្យាស្ថាន វ៉ាន់ដា៖ របាយការណ៍បញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់របស់និស្សិតជំនាន់ ១៨ ឈ្មោះវ៉ែន រដ្ឋា ទំព័រទី ៩

សណ្ឋាគារនេះ សំដៅទៅលើការផ្គត់ផ្គង់សេវាស្នាក់នៅ នាមលក្ខណៈជាបន្ទប់ គ្រែ និងមានការផ្តល់នូវសម្បទា និងសេវាផ្សេងៗទៀតទៅតាមប្រភេទនៃមូលដ្ឋានសេវាស្នាក់នៅនីមួយៗ ដូចជា កន្លែងបោះជុំរុំទេសចរណ៍(Tourist Camping) ឬរីស៊ត បឹងកាឡូ និងទីកន្លែងផ្តល់សេវាស្នាក់នៅដទៃទៀត ដែលមានលក្ខណៈប្រហាក់ប្រហែលទោះបីជាឱ្យ ឬដាក់ឈ្មោះថាជាអ្វីក៏ដោយ។

អាករស្នាក់នៅត្រូវដល់កំណត់ និងបង់ពន្ធនៅពេលផ្គត់ផ្គង់សេវាស្នាក់នៅ ឧទាហរណ៍ម្ចាស់សណ្ឋាគារ ឬអ្នកតំណាងមានកាតព្វកិច្ចប្រមូលប្រាក់អាករនេះពីភ្ញៀវ និងបង់ជូនរដ្ឋបាលសារពើពន្ធ។ អ្នកជាប់ពន្ធតាមប្រព័ន្ធស្វ័យប្រកាសត្រូវបង់អាករ និងដាក់លិខិតប្រកាសប្រចាំខែយ៉ាងយូរបំផុត នៅត្រឹមថ្ងៃទី២០នៃខែបន្ទាប់ជូនរដ្ឋបាលសារពើពន្ធ។

មូលដ្ឋានគិតជាអាករ គឺជាថ្លៃបន្ទប់ស្នាក់នៅក្នុសណ្ឋាគារ ដោយរួមបញ្ចូនទាំងពន្ធ-អាករ និងបន្ទុកសេវាផ្សេងៗប៉ុន្តែត្រូវលើកលែងអាករលើតម្លៃបន្ថែម និងអាករស្នាក់នៅខ្លួនឯង។

សណ្ឋាគារ សំដៅលើការផ្គត់ផ្គង់សាវ៉ាស្នាក់នៅ មានលក្ខណៈជាបន្ទប់ គ្រែ និងមាននូវសម្បទា និងសេវាផ្សេងៗ ទៀត ទៅតាមប្រភេទនៃមូលដ្ឋានស្នាក់នៅ ដូចជា៖

- សណ្ឋាគារ ៖ អាគារស្នាក់នៅ ដែលផ្តល់សេវាស្នាក់នៅពេញលេញមានភោជនីដ្ឋាន សេវាបំរើអាហារ សេវាបោកគក់.....
- សណ្ឋាគារអាផាតមិុន ៖ សណ្ឋាគារ ដែលមានបំពាក់សម្ភារៈ ផ្ទះបាយ និងមានបន្ទប់ទទួលភ្ញៀវ
- សណ្ឋាគារស្វីត ៖ សណ្ឋាគារបន្ទប់ទាំងអស់សុទ្ធតែស្វីត
- សណ្ឋាគាររីសត ៖ សណ្ឋាគារដែលសង់ក្នុងតំបន់ទេសចរណ៍
- ម៉ូតែល ៖ អាគារស្ថិតនៅតំបន់ជាយក្រុង សេវាមានកម្រិត
- ឡូជ ៖ អាគារ ដែលមានទីតាំងស្ថិតនៅតំបន់សំរាករីស្សមកាល
- បឹងកាឡូ ៖ អាគារ មានបន្ទប់ដេក បន្ទប់ទទួលភ្ញៀវ ចំណតរថយន្ត
- ផ្ទះសំណាក់ ឬផ្ទះភ្ញៀវ ៖ អាគារ ទទួលភ្ញៀវគ្រប់ប្រភេទ
- កន្លែងបោះជំរុំទេសចរណ៍ ៖ កន្លែងបង្កើតក្នុងតំបន់ទេសចរណ៍

### ២.៣.៣ ប្រភេទនៃអាករ

អាករលើតម្លៃបន្ថែម (VAT) ជាប្រភេទពន្ធប្រយោល ដែលរដ្ឋដកហូតប្រយោលពីអ្នកប្រើប្រាស់តាមរយៈអ្នកផ្គត់ផ្គង់ជាបុគ្គលជាប់អាករ។ អាត្រា 0% សម្រាប់ការនាំចេញ ឬ ផ្គត់ផ្គង់ក្រៅកម្ពុជា និងអាត្រា ១០% សម្រាប់ការផ្គត់ផ្គង់ក្នុងស្រុក។ VAT ដកហូតនៅពេលចេញ Invoice, Debit Note and Credit Not។
VAT គឺដកហូតពីអ្នកប្រើប្រាស់តាមរយៈអ្នកផ្គត់ផ្គង់បុគ្គលជាប់អាករ[8]។

អាករលើតម្លៃបន្ថែមគឺជាអាករកំណត់ទៅលើការចំណាយទិញរបស់ប្រើប្រាស់អាករនេះត្រូវប្រមូលពីកាប្រកបអាជីវកម្ម និងការនាំចូល។

ការប្រកបអាជីវកម្មភាគច្រើនទាក់ទិនទៅនឹងការផ្គត់ផ្គង់ទំនិញ ឬសេវា។ ការប្រកបអាជីវកម្មទាំងនោះត្រូវជាប់ អាករលើតម្លៃបន្ថែមប្រសិនបើការផ្គត់ផ្គង់៖

- ធ្វើឡើងក្នុងព្រះរាជាណាចក្រកម្ពុជា

[8] www.tax.gov.kh (13 01 2024)

- ធ្វើឡើងដោយបុគ្គលជាប់អាករ
- ធ្វើឡើងក្នុងដំណាក់កាលប្រកបអាជីវកម្ម ឬដំណាក់កាលពង្រីកអាជីវកម្ម
- គ្មានការបញ្ជាក់ច្បាស់លាស់ថាមិនជាប់អាករ ឬជាប់អាករតាមអាត្រា ០%ការផ្គត់ផ្គង់ធ្វើឡើងដោយបុគ្គលជាប់អាករនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលមិនមែនជាការផ្គត់ផ្គង់ មិនជាប់អាករ ហៅថាការផ្គត់ផ្គង់អាប់អាករ[៩]។

អាករលើតម្លៃបន្ថែម គឺជាប្រភេទពន្ធប្រយោល ដែលរដ្ឋដកហូតប្រយោលពីអ្នកប្រើប្រាស់តាមរយៈអ្នកផ្គត់ផ្គង់ ក្នុងបុគ្គលជាប់អាករ ហើយពន្ធអាករលើតម្លៃបន្ថែមត្រូវបានកំណត់អាត្រាពន្ធ១០%។

❖ **សម្រាប់ការផ្គត់ផ្គង់ដែលមិនជាប់អាករ**

- សេវាប្រៃសនីយ៍សាធារណៈ
- សេវាមន្ទីរពេទ្យ និងគ្លីនិក សេវាខាងវេជ្ជសាស្រ្តនិកទន្តសាស្រ្ត និងការលក់ទំនិញបន្ទាប់បន្សំខាងវេជ្ជសាស្រ្ត និងទន្តសាស្ត្រដែលនិក និងការបំពេញសេវាទាំងនេះ។
- សេវាដឹកជញ្ជូនអ្នកដំណើរដោយប្រព័ន្ធដឹកជញ្ជូនសាធារណៈ ដែលជាកម្មសិទ្ធទាំងស្រុងរបស់រដ្ឋ
- សេវាធានារ៉ាប់រង
- សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ
- ការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃ
- សេវាអប់រំ
- ថាមពលអគ្គីសនី និងទឹកស្អាត
- សេវាប្រមូល ឬសម្អាតកាកសំណល់រឹងរាវ
- ការនាំចូលសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនដែលរួចពន្ធគយ
- សកម្មភាពមិនស្វែងរកចំណេញ ដើម្បីបម្រើប្រយោជន៍សាធារណៈដែលបានទទួលស្គាល់ដោយមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ការនាំចូល និងការទិញទំនិញសម្រាប់ដោយបេសកកម្មការទូត និងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា សម្រាប់យកមកប្រើក្នុងការបំពេញមុខងារជាផ្លូវការរបស់ខ្លួន[10]។

❖ **សម្រាប់ការផ្គត់ផ្គង់ដែលជាប់អាករ**

- ការផ្គត់ផ្គង់ទំនិញ ឬសេវាដោយបុគ្គលជាប់អាករនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ការដកទំនិញយកមកប្រើប្រាស់ផ្ទាល់ខ្លួនដោយបុគ្គលជាប់អាករ
- ការផ្តល់ជាអំណោយ ឬការផ្គត់ផ្គង់ក្រោមតម្លៃពិតនូវទំនិញ ឬសេវាដោយបុគ្គលជាប់អាករ
- ការនាំចូលទំនិញនៅក្នុងតំបន់ត្រួតពិនិត្យគយនៃព្រះរាជាណាចក្រកម្ពុជា។

❖ **ការទិញមិនអនុញ្ញាតឥណទាន**

---

[9] https://cambotax.com (13 01 2024)

[10] សៀវភៅច្បាប់ស្តីពីសារពើពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ ត្រង់ទំព័រទី ២៥

- អតប បង់លើការទិញ ឬនាំចូលរថយន្ត លើកលែងតែបុគ្គលជាប់អតបប្រកបអាជីវកម្មលក់ ឬជួលរថយន្ត ពាក្យថារថយន្ត សំដៅដល់រថយន្តសម្រាប់ដឹកអ្នកដំណើរមានកៅអីមិនលើសពី ១០ កៅអី។
- អតប ចំណាយលើដំណើរកំសាន្ត ឬសម្រាកលំហែកាយ លើកលែងតែបុគ្គលជាប់អតប មានអាជីវកម្មជាអ្នកផ្គតផ្គង់ការទទួលភ្ញៀវ។
- អតប បង់លើការទិញ ឬនាំចូលផលិតផលតេលសិលាមួយចំនួនលើកលែងតែបុគ្គលជាប់អតប ប្រកបអាជីវកម្មជាអ្នកផ្គត់ផ្គង់ផលិតផលតេលសិលាទាំងនោះ ផលិតផលតេលសិលាមានដូចជា៖ ប្រេងសាំង ប្រេងសាំងស៊ុបពែ ប្រេងម៉ាស៊ូត និងប្រេងរំអិល។
- អតប បង់លើសេវាទូរស័ព្ទចល័ត។

អាករលើតម្លៃបន្ថែម (Value-Added Tax , VAT) គឺជាអាករដែលកំណត់ទៅលើការចំណាយទិញ របស់ អ្នកប្រើប្រាស់ហើយអាករនេះត្រូវប្រមូលពីការប្រកបអាជីវកម្ម និងការនាំចូល។ ការប្រកបអាជីវកម្មភាគច្រើនទាក់ទិនទៅនឹងការផ្គត់ផ្គង់ទំនិញ ឬសេវា។ ការប្រកបអាជីវកម្មទាំងនេះ ត្រូវជាប់អាករលើតម្លៃបន្ថែមប្រសិនបើ ការផ្គត់ផ្គង់៖

- ធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ធ្វើឡើងដោយបុគ្គលជាប់អាករ (taxable person)
- ធ្វើឡើងក្នុងដំណាក់កាលប្រកបអាជីវកម្ម ឬ ជាប់អាករតាមអាត្រា0%
- គ្មានការបញ្ជាក់ច្បាស់លាស់ថា មិនជាប់អាករ ឬ ជាប់អាករតាមអាត្រា 0% បន្ថែមទៅទៀតសកម្មភាពពាណិជ្ជកម្មខាងក្រោមនេះ ក៏ត្រូវជាប់អាករលើតម្លៃបន្ថែមផងដែរដូចជា៖ លក់ដោយបញ្ចុះថ្លៃ ឬ ឥតគិតថ្លៃក្តី ឬ ការលក់ចេញពីម៉ាស៊ីនលក់ស្វ័យប្រវត្តិ
- ការលក់ទ្រព្យសកម្មដែលប្រើប្រាស់ក្នុងអាជីវកម្មដូចជា គ្រឿងសម្ភារៈបរិក្ខារ គ្រឿងសង្ហារឹម យានយន្តសម្រាប់អាជីវកម្ម ។ល។
- ការឱ្យជួល ឬ ឱ្យខ្ចីទំនិញទៅបុគ្គលម្នាក់ទៀត
- ការជូនអំណោយទៅមិត្តភក្តិ ឬ អ្នកតំណាងអាជីវកម្ម
- ការដកយកទំនិញទៅប្រើប្រាស់សម្រាប់ជាផលប្រយោជន៍ផ្ទាល់របស់លោកអ្នក និងគ្រួសារ
- កម្រៃដែលបានមកពីការលក់អ្វីមួយក្នុងនាមបុគ្គលផ្សេងទៀត
- ការផ្គត់ផ្គង់ដែលបានធ្វើឡើងដោយបុគ្គលជាប់អាករ (Taxable person) នៅព្រះរាជាណាចក្រកម្ពុជាដែលមិនមែនជាការផ្គត់ផ្គង់មិនជាប់អាករហៅថា ការផ្គត់ផ្គង់ជាប់អាករ (Taxable person)។ បុគ្គលជាប់អាករ (Taxable Person) គឺជារូបវន្តបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធ ក្រុមហ៊ុនមហាជន ឬបុគ្គលណាមួយដែលមានផលរបរបានពីការផ្គត់ផ្គង់ជាប់អាករលើសពីកម្រិតអប្បបរមានៃផលរបរត្រូវចុះបញ្ជីអាករលើតម្លៃបន្ថែម។

ការផ្គត់ផ្គង់ត្រូវនៅក្រៅដែនអនុវត្តអាករលើតម្លៃបន្ថែមប្រសិនបើការផ្គត់ផ្គង់នោះ ៖

- ធ្វើឡើងដោយបុគ្គលដែលមិនមែនជាបុគ្គលជាប់អាករ ឬ មិនធ្វើឡើងក្នុងដំណាក់កាលប្រកប

អាជីវកម្ម ឬដំណាក់កាលពង្រីកអាជីវកម្ម អត្រានៃអាករលើតម្លៃបន្ថែមមានពីរគឺ អត្រាស្តង់ដា (១០%) និងអត្រាសូន្យ(០%)។ ចំពោះការនាំទំនិញ ចេញពីព្រះរាជាណាចក្រកម្ពុជា ការផ្គត់ផ្គង់សេវាជាប់អាករដែលបានធ្វើនៅក្រៅព្រះរាជាណាចក្រកម្ពុជា និងការដឹកជញ្ជូនទំនិញ ឬអ្នកដំណើរជាអន្តរជាតិ ព្រមទាំងទំនិញ និងសេវាដែលទាក់ទិននឹងការនាំចេញ និងការដឹកជញ្ជូនអ្នកដំណើរជាអន្តរជាតិត្រូវជាប់អាករតាមអត្រាសូន្យ(០%)។

អត្រាសូន្យ អនុវត្តចំពោះការផ្គត់ផ្គង់ ៖

- ទំនិញនាំចេញពីកម្ពុជា
- ការផ្គត់ផ្គង់សេវាសម្រាប់នៅក្រៅកម្ពុជា
- សេវាទាក់ទិននឹងការដឹកជញ្ជូនអ្នកដំណើរ និងទំនិញជាអន្តរជាតិ
- ការដឹកជញ្ជូនអ្នកដំណើរ និងទំនិញជាអន្តរជាតិតាមផ្លូវគោក ផ្លូវទឹក ឬផ្លូវអាកាស នៅពេលការដឹកជញ្ជូននោះត្រូវបានធ្វើឡើង៖
    - ពីកន្លែងមួយក្នុងកម្ពុជា ទៅក្រៅកម្ពុជា
    - ពីកន្លែងមួយនៅក្នុងកម្ពុជា មកក្នុងកម្ពុជា
    - ពីកន្លែងមួយនៅក្រៅកម្ពុជា ទៅក្រៅកម្ពុជា

# ជំពូកទី៣
# លទ្ធផលនៃការស្រាវជ្រាវ

# ជំពូកទី៣
# ការប្រមូលអាករបំភ្លឺសាធារណៈរបស់ អគ្គនាយកដ្ឋានពន្ធដារ

## ៣.១ ស្ថានភាពទូទៅនៃអគ្គនាយកដ្ឋានពន្ធដារ




### ៣.១.១ ប្រវត្តិអគ្គនាយកដ្ឋានពន្ធដារ

ប្រព័ន្ធពន្ធដារត្រូវបានលុបបំបាត់ចោលនៅក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដោយសារមានការកើតមានឡើងនៅសង្គ្រាម(របបខ្មែរក្រហម ឬរបបប៉ុល ពត) និងបានធ្វើអោយប្រជាជនជួបនៅភាពលំបាក ការបាត់បង់ជីវិតជាច្រើននាក់ផងដែរ។ ប្រព័ន្ធពន្ធដារត្រូវបានបង្កើតឡើងវិញដំបូងនៅឆ្នាំ១៩៨២ដែលបានអនុវត្តឡើងនៅរាជធានីភ្នំពេញ និងខេត្តចំនួន១០ផ្សេងទៀតដែលគេហៅថា របបម៉ៅការហើយបានគ្រប់គ្រងដោយនាយកដ្ឋាន

ពន្ធដារ។ លើសពីនេះទៅទៀត នាយកដ្ឋានពន្ធដារបានបង្កើតពន្ធមួយចំនួនផ្សេងទៀតដើម្បីអនុវត្ត និងមានការបែងចែកច្បាប់ និងមាត្រាយ៉ាងច្បាស់លាស់។ ពន្ធទាំងនោះរួមមាន៖

- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩ ប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១.៩៩/០១ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ចែងអំពីការអនុញ្ញាតអោយប្រមូលអាករបំភ្លឺសាធារណៈលើតម្លៃសុរាមេរ៉យ និងបារី ដែលជាផលិតផលមកពីបរទេស។
- ពន្ធប៉ាតង់ ត្រូវបានអនុលោមតាមខ្លឹមសារក្រឹតច្បាប់លេខ ២២ ក្រ.ច ចុះនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ១៩៩៤ ស្តីពីពន្ធប៉ាតង់និងមាត្រា ៣៩ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥ ដែលប្រកាសដោយព្រះរាជក្រមលេខ ១១ ន.ស៩៤ ចុះនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ។
- ពន្ធលើប្រាក់បៀវត្ស ចាប់ផ្តើមដំបូងគឺ ចេញពីព្រះរាជក្រមលេខ ១១ ន.ស៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៩៤ (ច្បាប់ស្តីពី ហិរញ្ញវត្ថុឆ្នាំ១៩៩៥) តែត្រូវបានធ្វើវិសោធនកម្មដ៏ធំនៅឆ្នាំ១៩៩៧។
- ពន្ធកាត់ទុក ចាប់ផ្តើមគឺចេញពីព្រះរាជក្រមលេខ នស.រកម ០២៩៧ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ (ច្បាប់ស្តីពី ហិរញ្ញវត្ថុឆ្នាំ១៩៩៥) តែត្រូវបានធ្វើវិសោធនកម្មដ៏ធំនៅឆ្នាំ១៩៩៧។
- ច្បាប់ស្តីពីការវិនិយោគនៃព្រះរាជណាចក្រកម្ពុជា ចុះថ្ងៃទី៤ ធ្នូ ឆ្នាំ១៩៩៧ ចេញដោយព្រះរាជក្រម និងអនុក្រឹតលេខ ៨៨អនុក្រ.បក ថ្ងៃទី២៩ ធ្នូ១៩៩៧ ស្តីពីការអនុវត្តច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។
- អាករលើតម្លៃបន្ថែមត្រូវបានអនុម័តដោយព្រះរាជក្រមលេខ នស.រកម ០២៩៧ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ១៩៩៧ តែអនុម័តពិតប្រាកដ គឺថ្ងៃ១ ខែមករា ឆ្នាំ១៩៩៩។
- អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា៤ និង៦ថ្មីនៃច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានធ្វើវិសោធនកម្មដោយមាត្រា ១១នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ដែលប្រកាសប្រើដោយព្រះរាជក្រមលេខ នស.រកម. ១២១៥/០១៦ ចុះថ្ងៃទី១៧ ធ្នូ ២០១៥ និងប្រកាសលេខ១៨២០ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពីការកំណត់វិធាន និងនីតិវិធីនៃការអនុវត្តបញ្ជីគណនេយ្យសាមញ្ញ សម្រាប់អ្នកជាប់ពន្ធតូច។
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧ : វិសោធនកម្មមាត្រា ៧ នៃច្បាប់ស្តីពីសារពើពន្ធទៅជាមាត្រា ៧ ថ្មី ដោយកំណត់ចំណេញមូលធនជាប្រាក់ចំណេញជាប់ពន្ធ
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩ : វិសោធនកម្មបន្ថែមលើមាត្រា ៧ ថ្មីទៅជាមាត្រា ៧ ថ្មី (មួយ)

សរុបរួមប្រវត្តិរបស់អង្គភាពពន្ធដារ

- ១៩៥៣ ត្រូវបានបង្កើតឡើងជានាយកដ្ឋានពន្ធដារ
- ១៩៧០ដល់១៩៧៩ ពន្ធដារត្រូវលុបបំបាត់ចោលដោយរបបប៉ុល ពត
- ១៩៨០ នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងវិញ
- ២០០៨ នាយកដ្ឋានពន្ធដារបានដំឡើងទៅជាអគ្គនាយកដ្ឋានពន្ធដារ

**៣.១.២ ចក្ខុវិស័យ បេសកកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ**

- ផ្តល់សេវាដល់អ្នកជាប់ពន្ធ រួមមានការផ្តល់ព័ត៌មាន អប់រំ ពន្យល់ណែនាំ ដើម្បីឱ្យអ្នកជាប់ពន្ធប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- អនុវត្តកម្មវិធីចាប់បង្ខំ ដោយការធ្វើសវនកម្ម ការអនុវត្តន៍វិធានការតឹងទារ និងអនុវត្តទោសទណ្ឌតាមការកំណត់នៃបទប្បញ្ញត្តិស្តីពីពន្ធដារចំពោះអ្នកជាប់ពន្ធដែលមិនបានប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- ប្រមូលចំណូលពន្ធ តាមការអនុវត្តន៍ត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និងបង់គ្រប់គ្រាន់ចូលថវិកាជាតិ
- ផ្តល់សេវា និងការអប់រំអ្នកជាប់ពន្ធ ដើម្បីធានាឱ្យច្បាប់នានាស្តីពីពន្ធដារត្រូវបានគោរព និងអនុវត្តត្រឹមត្រូវ
- អនុវត្តកម្មវិធីចាប់បង្ខំប្រកបដោយប្រសិទ្ធភាព មានការទទួលខុសត្រូវខ្ពស់ និងស្មើរភាព ចំពោះអ្នកជាប់ពន្ធ ដែលមិនគោរពច្បាប់ និងបទប្បញ្ញាត្តិស្តីពីសារពើពន្ធ
- អនុវត្តគោលការណ៍យុត្តិធម៌ក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ដើម្បីបង្កើនការជឿទុកចិត្ត ចំពោះរដ្ឋបាលសារពើពន្ធ
- បន្ថយការចំណាយរបស់រដ្ឋបាលសារពើពន្ធ ក្នុងការរៀបចំកម្មវិធី និងកិច្ចដំណើរការរបស់ខ្លួនធ្វើឱ្យមានភាពសាមញ្ញចំពោះតម្រូវការផ្សេងៗ និងបន្ថយការចំណាយរបស់អ្នកជាប់ពន្ធ
- បង្កើនសមត្ថភាព ចំណេះដឹងដល់មន្ត្រីពន្ធដារ ដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាព
- បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងតាមរយៈគោលនយោបាយ កិច្ចដំណើរការការងារ និងប្រព័ន្ធការងារដែលមានភាពច្បាស់ ទំនើប និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន

**៣.១.៣ អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ចជាអាទិ៍ដូចតទៅ៖**

- រៀបចំគោលនយោបាយសារពើពន្ធ និងការប្រមូលពន្ធគ្រប់ប្រភេទបង់ចូលថវិការជាតិ
- រៀបសេចក្តីព្រាងច្បាប់លិខិតបទដ្ឋាននានាស្តីពីពន្ធដារកំណត់បញ្ជីឯកសារចាំបាច់នានា និងលិខិតយុត្តិការ ដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់កាប់រក្សាទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ
- កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកដោយផ្អែកលើការអង្កេតនិងផ្តុំព័ត៌មាន
- គណនានិងប្រមូលប្រាក់ពន្ធ ប្រាក់បន្ថែម និងចំណូលផ្សេងៗ
- កសាងកម្មវិធី និងអនុវត្តការងារសវនកម្មចំពោះអ្នកជាប់ពន្ធ
- ទទួលបន្ទុកសហប្រតិបត្តិការអន្តជាតិក្នុងផ្នែកពន្ធដារ
- អនុវត្តទោសទណ្ឌតាមច្បាប់ចំពោះអ្នកជាប់ពន្ធ និងភ្នាក់ងារកាត់ទុកដែលល្មើសបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- ចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ

### ៣.១.៤ និមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារ

### ៣.១.៥ រចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ

- ឯកឧត្តម គង់ វិបុល រដ្ឋមន្ត្រីប្រតិភូរាជរដ្ឋាភិបាលអមនាយករដ្ឋមន្ត្រី ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ
- ឯកឧត្តម អ៊ុំ សីហា អគ្គនាយករង
- ឯកឧត្តម ជាប ដារ៉ុជ អគ្គនាយករង
- លោក លឹម ជឺលុច្ស អគ្គនាយករង
- ឯកឧត្តម មិញ បានកុសល អគ្គនាយករង
- ឯកឧត្តម កែន សម្បត្តិ អគ្គនាយករង
- ឯកឧត្តម ហេង សុខណាង អគ្គនាយករង
- លោកជំទាវ ប៊ុន នារី អគ្គនាយករង
- ឯកឧត្តម លឹម ហ៊ុយជីវ អគ្គនាយករង
- ឯកឧត្តម រ័ត្ន មុនី អគ្គនាយករង


អគ្គនាយកដ្ឋានពន្ធដារ
General Department of Taxation

## ៣.២ ការកំណត់ពន្ធនៃអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ

### ៣.២.១ ការបង្កើតអាករបំភ្លឺសាធារណៈ

អាករបំភ្លឺសាធារណៈត្រូវបានបង្កើតឡើងដោយច្បាប់ ស្តីពីច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ គឺមាត្រា២៣ ។ ប៉ុន្តែមាត្រា២៣ នេះត្រូវបានប្តូរទៅជាមាត្រា២៣ថ្មី ដោយការធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០០ ចំពោះតម្លៃសុរាមេរ័យ និងបារី ដែលលក់នៅក្នុងមណ្ឌលដែនដីខេត្ត-ក្រុង។ ដូចនេះមាត្រា២៣ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ ត្រូវទុកជានិរាករណ៍។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញសេចក្តីជូនដំណឹងមួយលេខ០០៤ សហវ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រង និងការប្រមូលអាករបំភ្លឺសាធារណៈ។ សេចក្តីជូនដំណឹងនេះ មិនបានចុះក្នុង រាជកិច្ចទេ។

យើងសង្កេតឃើញមានប្រកាសអន្តរក្រសួងមួយលេខ ១៧៥ សហវ.ពដ.ប្រក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រង និងការប្រមូលអាករបំភ្លឺសាធារណៈ។ ប្រកាសនេះធ្វើឡើងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ។ ប្រកាសមួយនេះបានដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការធ្វើនិយ័តកម្មលើការអនុវត្តន៍ និងការប្រមូលអាករបំភ្លឺសាធារណៈ Tax on public lighting ។

ប្រកាស៧ នៃប្រកាសលេខ ១៧៥ ខាងលើ ប្បញ្ញត្តិថាប្រាក់ចំណូលដែលបានមកពីការប្រមូលអាករបំភ្លឺសាធារណៈត្រូវបានជាប្រយោជន៍ថវិកាខេត្ត-ក្រុង ទុកសម្រាប់ចំណាយឱ្យការបំភ្លឺសាធារណៈ។

### ៣.២.២ បុគ្គលជាប់អាករ

បុគ្គលដែលធ្វើការផ្គត់ផ្គង់សុរាមេរ័យ និងបារី គឺជាបុគ្គលជាប់អាករបំភ្លឺសាធារណៈ និងទទួលខុសត្រូវចំពោះអាករនេះ។ បុគ្គលជាប់អាករ taxpayer ត្រូវប្រមូលអាករបំភ្លឺសាធារណៈ Tax on public lighting នេះពីអតិថិជនរបស់ខ្លួន និងយកប្រាក់អាករនេះ ទៅបង់ជូនការិយាល័យគ្រប់គ្រងប្រមូលពន្ធតាមរបបពិតចំពោះបុគ្គលជាប់អាករតាមរបបពិត real regime taxpayer ឬសាខាពន្ធដារ ខេត្ត-ក្រុង ។

ចំពោះការដកយកសុរាមេរ័យ និងបារី សម្រាប់តម្រូវការផ្ទាល់ខ្លួនរបស់បុគ្គលជាប់អាករ របស់បុគ្គលិក ឬសម្រាប់តតិយជន ត្រូវជាប់អាករបំភ្លឺសាធារណៈផងដែរ។ បុគ្គលជាប់អាករតាមរបបពិត real regime taxpayer ត្រូវដាក់លិខិតប្រចាំខែ monthly tax declaration យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ហើយត្រូវបង់ប្រាក់អាករនេះទៅតាមចំនួនដែលបានប្រកាស នៅពេលដាក់លិខិតប្រកាសនេះ។ ដូចនេះអាករបំភ្លឺសាធារណៈ Tax on public lighting គឺជាពន្ធប្រចាំខែ monthly tax ។

### ៣.២.៣ ទំនិញជាប់អាករ

យោងតាមប្រកាស២ នៃប្រកាសលេខ ១៧៥ សហវ.ពដ.ប្រក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រង និងការប្រមូលអាករបំភ្លឺសាធារណៈ ត្រូវបានចាត់ទុកជាសុរាមេរ័យ និងបារី រួមមាន៖

1 .ស្រាបៀរ

2 .ស្រាទំពាំងបាយជូរស្រស់ រួមទាំងស្រាទំពាំងបាយជូរមានបន្ថែមជាតិសុរា

3 .ស្រាវ៉ែមុត និងស្រាទំពាំងបាយជូរស្រស់ផ្សេងទៀតផ្សំពីរុក្ខជាតិ និងសារជាតិក្រអូប

4 .ភេសជ្ជៈមេរ័យផ្សេងៗ លើកលែងតែទឹកខ្មេះតជូរ និងស្រាស

5 .អាល់កុលអេទីលិកសុទ្ធមានកម្រិតជាតិសុរាក្នុងឯកតាចំណុះពី៨០៥ នៃចំណុះ ឬលើសពីនេះ និងអាល់កុល អេទីលិក ហើយនិងភេសជ្ជៈមានជាតិសុរាដែលបាត់បង់កម្រិតសុរាដើមរបស់វា

6 .អាល់កុលអេទីលិកបាត់បង់ជាតុសុទ្ធដែលមានកម្រិតជាតិសុរាក្នុងឯកតាសំណុះទី៨០៥ នៃចំណុះ និងភេសជ្ជៈមានជាតិស្រវឹងផ្សេងៗទៀត ការរៀបចំកែច្នៃសុរាផ្សំក្នុងប្រភេទដែលប្រើសម្រាប់ផលិតភេសជ្ជៈ

7 .បារី បារីស៊ីហ្គា គ្រប់ប្រភេទ។

**៣.២.៣ ទំនិញជាប់អាករ**

ក. វិធានទូទៅ នៃការគណនាអាករត្រូវបង់

តាមមាត្រា ២៣ថ្មី នៃច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០២ អាករបំភ្លឺសាធារណៈត្រូវបានប្រមូលលើតម្លៃសុរាមេរ៉ៃ និងបារី ដែលលក់ក្នុងមណ្ឌលដែនដីខេត្ត-ក្រុងនីមួយៗ។

ដើម្បីគណនាប្រាក់អាករត្រូវបង់ បុគ្គលជាប់អាករ taxpayer ត្រូវធ្វើការបែងចែកឱ្យបានរវាងផលរបរដែលបានមកពីការផ្គត់ផ្គង់សុរាមេរ៉ៃ និងបារី ជាប់អាករ និងផលរបរបានមកពីការផ្គត់ផ្គងទំនិញ ឬសេវាដទៃទៀត។ ក្នុងករណីដែលបុគ្គលជាប់អាករតាមរបបម៉ៅការ estimated regime taxpayer ពុំអាចធ្វើការបែងចែកផលរបរបានមន្ត្រីពន្ធត្រូវពិភាក្សាជាមួយបុគ្គលជាប់អាករ ដើម្បីកំណត់សមាមាត្រនៃផលរបរបានមកពីការផ្គត់ផ្គង់ សុរាមេរ៉ៃ និងបារីជាប់អាករ។ សមាមាត្រនេះ ត្រូវពិនិត្យ និងសម្រេចដោយប្រធានសាខាពន្ធដារខេត្ត-ក្រុង។

អាករនេះត្រូវកំណត់នៅគ្រប់ដំណាក់កាលផ្គត់ផ្គង់ និងត្រូវអនុវត្តលើតម្លៃផ្គត់ផ្គង់ផលិតផលជាប់អាកររួមបញ្ចូលទាំងពន្ធអាករនានា លើកលែងតែអាករសម្រាប់បំភ្លឺសាធារណៈខ្លួនឯង និងអាករលើតម្លៃបន្ថែមចំពោះបុគ្គលជាប់អាករតាមរបបពិត (ស្វ័យប្រកាស) real regime taxpayer ។ ដូចនេះមូលដ្ឋានគិតអាករ Tax base គឺជាចំនួនផលរបរ ដែលអនុញ្ញាតឱ្យកាត់ចេញនូវអាករបំភ្លឺសាធារណៈ Tax on public lighting ខ្លួនឯង និងអាករលើតម្លៃបន្ថែម Value added tax ឬអាករលើផលរបរ Turnover tax ។

ខ. ចំពោះបុគ្គលជាប់អាករតាមរបបស្វ័យប្រកាស

| |
|---|
| អាករបំភ្លឺសាធារណៈត្រូវបង់ = មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ x អាត្រា |

| |
|---|
| មូលដ្ឋានគិតVAT = មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ / ១.១ |

| |
|---|
| មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ = មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ / ១.០៣ |

ឧទាហរណ៍ ៖ អ្នកផ្គត់ផ្គង់សុរាមេរ៉ៃ និងបារីទទួលបានផលរបរប្រចាំខែរួមមាន សុរាមេរ៉ៃចំនួន ១៥០រៀល និងបារីចំនួន ១០០រៀល។

- មូលដ្ឋានគិតអាករលើតម្លៃបន្ថែម = ២៥០រៀល / ១.១ = ២២៧.២៧រៀល
- មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ = ២២៧.២៧រៀល / ១.០៣ = ២២០.៦៥រៀល
- អាករត្រូវបង់ = ២២០.៦៥រៀល x ៣% = ៦.៦១

## ៣.៣ វិធី នៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ

កាលពីមុនអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ធ្វើការបង់ប្រាក់ពន្ធ និងស្នើសុំទម្រង់លិខិតប្រកាសពន្ធ នៅតាមសាខាពន្ធដារខណ្ឌរៀងៗខ្លួន។ ប៉ុន្តែដោយមានភាពលំបាកពេកសម្រាប់មន្ត្រីពន្ធក៏ដូចជាអ្នកជាប់ពន្ធរាជរដ្ឋាភិបាលកម្ពុជាបានធ្វើកំណែទម្រង់មួយចំនួនដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយធ្វើការផ្លាស់ប្តូរ នីតិវិធីក្នុងការប្រមូលពន្ធ-អាករ និងការដាក់លិខិតប្រកាសពន្ធផ្សេងឱ្យមានលក្ខណៈទំនើប និងងាយស្រួលសម្រាប់អ្នកជាប់ពន្ធនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

### ៣.៣.១ ការប្រមូលប្រាក់អាករ

ការប្រមូលប្រាក់អាករនាពេលបច្ចុប្បន្ន ក៏ដូចជាការប្រមូលប្រាក់ពន្ធដទៃទៀតដែរ គឺអ្នកជាប់ពន្ធទាំងអស់ត្រូវធ្វើការគណនាពន្ធដោយខ្លួនឯង បំពេញលិខិតប្រកាសបង់ពន្ធ ហើយធ្វើការបង់នៅតាមធនាគារដើម្បីផ្តល់សុវត្ថិភាពដល់ថវិការដ្ឋ។

❖ **ជម្រើសទី១**

ដើម្បីភាពងាយស្រួលនិងឆាប់រហ័សទាន់ចិត្តអ្នកជាប់ពន្ធអាចចូលទៅក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh ដោយស្វែងរកពាក្យ «ការប្រកាសបង់ប្រាក់ពន្ធ» ហើយអនុវត្តតាមលំដាប់លំដោយ និងការណែនាំនៅក្នុងគេហទំព័រដូចខាងក្រោម៖

- បំពេញការិយាបរិច្ឆេទ នៃការបង់ពន្ធរបស់ខ្លួន(ខែ ឆ្នាំ ពីថ្ងៃ ដល់ថ្ងៃ)ឧទាហរណ៍៖ ខែកក្កដា ឆ្នាំ ២០១៩ ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃ៣១
- ជ្រើសរើសប្រភេទពន្ធ និងបំពេញចំនួនទឹកប្រាក់ពន្ធដែលត្រូវបង់តាមប្រភេទពន្ធនីមួយៗដូចក្នុងលិខិតប្រកាស
- ជ្រើសរើសកម្រៃសេវាផ្សេងៗ និងបំពេញទឹកប្រាក់ដែលត្រូវបង់ (ប្រសិនបើមាន)។
- ត្រូវបំពេញចំនួនទំព័រនៃទម្រង់លិខិតប្រកាសនីមួយៗ
- នៅពេលបំពេញរួចត្រូវបោះពុម្ព (Print) លិខិតស្នើសុំបង់ប្រាក់ពន្ធចេញពីប្រព័ន្ធគ្រប់គ្រងដែលមាន Barcode សម្រាប់សម្គាល់ចេញពីម៉ាស៊ីនបោះពុម្ព (Print) ហើយអ្នកជាប់ពន្ធអាចយកលិខិតនេះទៅបង់ពន្ធ នៅធនាគារណាមួយដែលទទួលបន្ទុកទទួលប្រាក់បង់ពន្ធ។

❖ **ជម្រើសទី២**

ក្នុងករណីអ្នកជាប់ពន្ធមិនសូវចេះប្រើប្រាស់កុំព្យូទ័រ និងប្រព័ន្ធ Online អ្នកជាប់ពន្ធត្រូវទៅធនាគារណាមួយទទួលបន្ទុកទទួលប្រាក់បង់ពន្ធ ហើយអនុវត្តតាមជំហាននីមួយៗដូចខាងក្រោម៖

- បំពេញទម្រង់បង់ប្រាក់ពន្ធ (From101) នូវប្រភេទពន្ធ និងចំនួនទឹកប្រាក់ពន្ធដែលត្រូវបង់តាមប្រភេទពន្ធនីមួយៗដូចក្នុងលិខិតប្រកាស
- ដាក់ទម្រង់បង់ប្រាក់ពន្ធ (From101) ដែលបំពេញរួចជូនមន្ត្រីធនាគារដើម្បីបង់ប្រាក់ពន្ធ។ ធនាគារដែលទទួលខុសត្រូវក្នុងការប្រមូលពន្ធជូនរដ្ឋមានដូចជា៖ ធនាគារអេស៊ីលីដា ,ធនាគារ

កាណាឌីយ៉ា ក.អ ,ធនាគារវឌ្ឍនៈ, ធនាគារ វឌ្ឍនៈ អាស៊ីចំកាត់, ធនាគារ កម្ពុជាសាធារណៈ ,ធនាគារ ស្ថាបនា ល។

ឧទាហរណ៍តារាង ៖ លេខគណនីរបស់ធនាគារមួយចំនួន ៖

| ធនាគារ | លេខគណនី | ប្រភេទឈ្មោះគណនី |
|---|---|---|
| អេស៊ីលីដា ភីអិលស៊ី | 2900-01677788-1-8 | ប្រាក់ពន្ធ-អាករគ្រប់ប្រភេទ |
| | 2900-01677777-1-7 | ប្រាក់ពន្ធលើអចលទ្រព្យ |
| | 2900-01655555-1-5 | ប្រាក់ទោសទណ្ឌ |
| កាណាឌីយ៉ា ក.អ | 0010002196676 | ប្រាក់ពន្ធ-អាករគ្រប់ប្រភេទ |
| | 0010002196692 | ប្រាក់ពន្ធលើអចលនទ្រព្យ |
| | 0010002196684 | ប្រាក់ទោសទណ្ឌ |
| ធនាគារ វឌ្ឍនៈ | 050-01-77-00-0801-9 | ប្រាក់ពន្ធ-អាករគ្រប់ប្រភេទ |
| | 050-01-77-00-0802-0 | ប្រាក់ពន្ធលើអចលនទ្រព្យ |
| | 050-01-77-00-0804-2 | ប្រាក់ទោសទណ្ឌ |

ក្រោយពេលទទួលប្រាក់ពន្ធគ្រប់ចំនួនរួចហើយ ភាគីធនាគារ ត្រូវបោះពុម្ព (Print) បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ (Tax Payment Receipt) ចេញពីប្រព័ន្ធគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារ ដែលមាន៣សន្លឹកគឺ ៖ សន្លឹកទី១ ពណ៌ស សម្រាប់មន្ត្រីពន្ធដាររក្សាទុក សន្លឹកទី២ ពណ៌ផ្កាឈូកសម្រាប់ប្រគល់ឱ្យអ្នកជាប់ពន្ធ និងសន្លឹកទី៣ ពណ៌លឿងសម្រាប់ធនាគារ។

លើសពីនេះទៅទៀតតាមរយៈកំណែទម្រង់ថ្មី ខាងអគ្គនាយកដ្ឋានពន្ធដារបានផ្តល់នូវសេចក្តីទុកចិត្តដល់សហគ្រាសដែលជាអ្នកជាប់ពន្ធដោយការជូនដំណឹងស្វ័យប្រវត្តិ (Automate and general SMS & Email) តាមរយៈការផ្ញើរសារ ឬតាម Email បញ្ជាក់ថាសហគ្រាសនោះបានបង់ប្រាក់ពន្ធ និងកាលបរិច្ឆេទដែលបានចែងក្នុងបង្កាន់ដៃបញ្ជាក់ការទទួលប្រាក់ពន្ធ បើសិនជាអ្នកជាប់ពន្ធដែលជាម្ចាស់សហគ្រាស បានផ្តល់លេខទូរស័ព្ទ និង Email មកអគ្គនាយកដ្ឋានពន្ធដារបានត្រឹមត្រូវ។ ចំណែកឯប្រភេទពន្ធនីមួយៗនិងទឹកប្រាក់សរុប គឺមានលម្អិតនៅក្នុងបង្កាន់ដៃបញ្ជាក់ការទទួលប្រាក់ពន្ធដែលចេញជាផ្លូវការ។

**លំហូរនៃទឹកប្រាក់ពន្ធចូលថវិកាជាតិ**




រូបភាពខាងលើមានអត្ថន័យដូចខាងក្រោម៖

គំនូសបំព្រួញទី១៖ អ្នកជាប់ពន្ធ ធ្វើការបង់ប្រាក់ នៅធនាគារទទួលបន្ទុកប្រមូលប្រាក់ពន្ធនីមួយៗ។

គំនូសបំព្រួញទី២៖ ក្រោយពីទទួលបានការបង់ប្រាក់ពន្ធអាករ ធនាគារធ្វើការផ្ទេរនូវទឹកប្រាក់ទាំងអស់ទៅរតនាគារជាតិនៃកម្ពុជា ដើម្បីទុកជាថវិការដ្ឋ សម្រាប់ការចំណាយផ្សេងៗ។

### ៣.៣.២ នីតិវិធីក្នុងការទទួលលិខិតប្រកាស

ក្រោយពីទទួលបានបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធហើយ អ្នកជាប់ពន្ធត្រូវភ្ជាប់បង្កាន់ដៃនេះ (សន្លឹកពណ៌ស សម្រាប់មន្ត្រីពន្ធដារ) ជាមួយលិខិតប្រកាសពន្ធដែលមានចុះហត្ថលេខា និងត្រាត្រឹមត្រូវ និងឯកសារពាក់ព័ន្ធនានា ដល់មន្ត្រីទទួលលិខិតប្រកាស នៅតាមអង្គភាពពន្ធដារទទួលបន្ទុក។

អង្គភាពពន្ធដារទទួលបន្ទុកនីមួយៗមានវិធីសាស្ត្ររៀងខ្លួនក្នុងការគ្រប់គ្រង ដើម្បីឱ្យការទទួលលិខិតប្រកាសពន្ធមានភាពងាយស្រួលនិងត្រឹមត្រូវ។

ដោយសារចំនួនក្រុមហ៊ុនដែលចុះបញ្ជីស្ថិតនៅក្រោមការគ្រប់គ្រង របស់អគ្គនាយកដ្ឋានពន្ធដារមានចំនួនច្រើនក្រុមហ៊ុន បានធ្វើឱ្យថ្នាក់ដឹកនាំនៃការិយាល័យចាត់ចែងទទួលលិខិតប្រកាសធ្វើការបែងចែកមន្ត្រីគ្រប់គ្រង និងទទួលលិខិតប្រកាសទៅតាមវិស័យដើម្បីផ្តល់ភាពងាយស្រួលដល់ការគ្រប់គ្រង និងការប្រមូលព័ត៌មាន។

-ក្រុមទី១៖ ធ្វើការទទួល និងពិនិត្យសារពើពន្ធក្នុងវិស័យ អាផាតម៉ិន សណ្ឋាគារ ផ្ទះសំណាក់ ភោជនីដ្ឋាន ក្លឹបកំសាន្ត និងសេវាកម្មដទៃទៀត។

-ក្រុមទី២៖ ទទួល និងពិនិត្យលិខិតប្រកាសសារពើពន្ធក្នុងវិស័យ អារហ័ណ នីរហ័ណ

-ក្រុមទី៣៖ ទទួល និងពិនិត្យលិខិតប្រកាសសារពើពន្ធក្នុងវិស័យកសិកម្ម សេវាកម្មសាងសង់ ស្ថាបត្យកម្ម ផលិតកម្មស្រាវជ្រាវរុករករ៉ែ សេវាកម្មទេសចរណ៍ ព័ត៌មានវិទ្យា ពិគ្រោះយោបល់ ផ្សាយពាណិជ្ជកម្ម ការិយាល័យតំណាង សាលារៀន និងអង្គការ សមាគមនានា។

-ក្រុមទី៤៖ ទទួល និងពិនិត្យលិខិតប្រកាសសារពើពន្ធសម្រាប់អ្នកជាប់ពន្ធតូចទាំងអស់។ ក្រោយពីទទួលបានលិខិតប្រកាសពន្ធចំនួនបីច្បាប់ពីអ្នកជាប់ពន្ធ មន្ត្រីទទួលលិខិតប្រកាសពន្ធធ្វើការពិនិត្យ ថាតើអ្នកជាប់ពន្ធបានបង់ត្រឹមត្រូវតាមការបំពេញនៅក្នុងលិខិតប្រកាសពន្ធ និងមានឯកសារយោងច្បាស់លាស់ភ្ជាប់ជាមួយដែរ ឬទេ។ ឧទាហរណ៍ សម្រាប់អាករបំភ្លឺសាធារណៈ មន្ត្រីពន្ធធ្វើការពិនិត្យលើចំណុចមួយចំនួនដូចខាងក្រោម៖

- ចំនួនទឹកប្រាក់ដែលអ្នកជាប់ពន្ធបង់ទៅធនាគារ ត្រូវស្មើនឹងចំនួនក្នុងលិខិតប្រកាស
- ទិន្នានុប្បវត្តិទិញលក់ត្រូវតែដូចនូវអ្វីដែលបំពេញក្នុងលិខិតប្រកាស
- វិក្កយបត្រអាករក្នុងករណីអ្នកជាប់ពន្ធស្នើរសុំឥណទានអាករជាតុចូល
- ហត្ថលេខា និងត្រាត្រូវតែមាននៅគ្រប់លិខិតប្រកាសអតប និងទិន្នានុប្បវត្តិទិញលក់។

ក្រោយពីធ្វើការពិនិត្យរួចរាល់ហើយបើសិនជាត្រឹមត្រូវដូចចំណុចរៀបរាប់ខាងលើ មន្ត្រីទទួលលិខិតប្រកាសធ្វើការចេញនូវលិខិតបញ្ជាក់ការទទួលលិខិតប្រកាស ហើយប្រគល់ឯកសារចំនួន១ច្បាប់ ទៅឱ្យអ្នកជាប់ពន្ធរក្សាទុក ក៏ដូចជាផ្ញើសារដោយស្វ័យប្រវត្តិទៅកាន់ម្ចាស់សហគ្រាសថាបានទទួលលិខិតប្រកាសរួចរាល់ហើយ។

ក្នុងករណីមន្ត្រីពន្ធពិនិត្យឃើញថា អ្នកជាប់ពន្ធធ្វើការប្រកាសពន្ធមិនមានភ្ជាប់ឯកសារត្រឹមត្រូវ ឬទឹកប្រាក់បង់ពន្ធខុសពីឯកសារភ្ជាប់មន្ត្រីពន្ធធ្វើការជូនដំណឹងទៅអ្នកជាប់ពន្ធភ្លាមៗឱ្យធ្វើការ កែតម្រូវឱ្យត្រឹមត្រូវវិញ។ ការចេញលិខិតបញ្ជាក់ ការទទួលលិខិតប្រកាសពន្ធមិនបញ្ជាក់ថាអ្នកជាប់ពន្ធបង់ប្រាក់ពន្ធត្រឹមត្រូវនោះទេលុះត្រាតែមន្ត្រីទទួលបន្ទុកធ្វើការពិនិត្យម្តងទៀត តាមរយៈការវាយបញ្ចូលនូវពន្ធ អាករដែលអ្នកជាប់

ពន្ធបានប្រកាស នៅក្នុងប្រព័ន្ធកត់ត្រាផ្ទៃក្នុងរបស់ពន្ធដារ ( Tax Collection System ) ដែលចងជារូបមន្តនិងគណនាចំនួនទឹកប្រាក់ពន្ធដោយស្វ័យប្រវត្តិ នោះនឹងដឹងថាសហគ្រាសណាដែលគណនា និងបង់ពន្ធត្រឹមត្រូវទៅតាមលិខិតប្រកាស។

ក្នុងករណីដែលពិនិត្យ និងផ្ទៀងផ្ទាត់ឃើញថាអ្នកជាប់ពន្ធធ្វើការគណនានិងបង់ត្រឹមត្រូវតាមលិខិតប្រកាសហើយ ខាងការិយាល័យចាត់ចែងលិខិតទទួលធ្វើការរក្សាទុកឯកសារមួយច្បាប់សម្រាប់បញ្ជូន ទៅអគ្គនាយកដ្ឋានពន្ធដារ និងមួយច្បាប់ទៀតទុកតម្កល់នៅសាខាពន្ធដារខណ្ឌដោយធ្វើការរក្សាទុករយៈពេល ១០ឆ្នាំ។ ករណីដែលពិនិត្យឃើញខុស ខាងមន្ត្រីទទួលបន្ទុកធ្វើការជូនព័ត៌មានឱ្យអ្នកជាប់ពន្ធធ្វើការកែ និងបង់ប្រាក់ពន្ធបន្ថែមតែក្នុងករណីមានកំហុសធ្ងន់ធ្ងរ និងមិនមានការសហការពីខាងអ្នកជាប់ពន្ធការិយាល័យចាត់ចែងលិខិតប្រកាសនិងធ្វើការបញ្ជូនព័ត៌មាននេះទៅឱ្យការិយាល័យសវនកម្មធ្វើការដោះស្រាយ។

ខាងក្រោមនេះ គឺជាទិន្នន័យនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងរយៈពេលប៉ុន្មានកន្លងទៅនេះ

| ចំនួនអ្នកជាប់ពន្ធ | ចំនួនពន្ធសរុប | អាករបំភ្លឺសាធារណៈ |
|---|---|---|
| ៥៧៥៩ | ១៨៩,៤៦២,០២៩,៤០៦ | ៦៧,៨៨៥,៩១៩,២៨០ |
| ៦០០៦ | ២៧៤,២៥៥,៣១៨,២៥៥ | ១១៦,៨៦៣,៤៨២,០៧២ |

ក្នុងរយៈពេលចុងក្រោយនេះរដ្ឋាភិបាលកម្ពុជាចាប់ផ្តើមរឹតបន្តឹងច្បាប់បង់ពន្ធបន្តិចម្តងៗ ជាក់ស្តែងឥឡូវនេះរដ្ឋាភិបាលបានជំរុញបន្ថែមទៀតឱ្យប្រជាពលរដ្ឋបង់ពន្ធប្រាក់ខែទៀត។ អ្នកដែលទទួលបានប្រាក់ខែក្នុងចន្លោះពី ១,៥០០,០០១រៀលដល់ ១២,៥០០,០០០ត្រូវជាប់កាតព្វបង់ពន្ធក្នុងចន្លោះពី ៥%ដល់២០%។

ក្រៅពីបង់ពន្ធលើប្រាក់ខែ ប្រជាពលរដ្ឋបង់ពន្ធលើអចលនទ្រព្យ ពន្ធមធ្យោបាយលើយានយន្ត ពន្ធលើប្រាក់ចំណេញ និងពន្ធផ្សេងៗទៀត។ ការបង់ពន្ធគឺជារឿងធម្មតាសម្រាប់ប្រទេសជឿនលឿន ប៉ុន្តែសម្រាប់ប្រទេសក្រីក្រដូចប្រទេសកម្ពុជាហាក់បីដូចជារឿងថ្មី ហើយពួកគេមិនចង់ចូលរួមបង់ពន្ធទេ។

**តើនេះបណ្តាលមកពីមូលហេតុអ្វី?**

កាលពីពេលមុនរដ្ឋាភិបាលនៃប្រទេសកម្ពុជាពឹងផ្អែកខ្លាំងទៅលើប្រាក់ចំណូលបានពីពន្ធគយសម្រាប់អភិវឌ្ឍន៍ប្រទេសជាតិ ប៉ុន្តែដោយសារពន្ធគយត្រូវបានប្រទេសក្នុងតំបន់អាស៊ានព្រមព្រៀងគ្នាកាត់បន្ថយបន្តិចម្តងៗក្នុងចំណោមសមាជិករបស់ខ្លួននោះ រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាចាប់ផ្តើមសម្លឹងរកប្រភពចំណូលផ្សេង ក្រៅពីប្រាក់ចំណូលពន្ធគយ។ ប្រាក់ចំណូលដែលរាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងសម្លឹងមើលសម្រាប់បំពេញថវិកាជាតិពេលខាងមុខនោះគឺប្រាក់ចំណូលពន្ធដារ។ ចំណូលពន្ធដារគឺជាប្រាក់ចំណូលដែលរដ្ឋាភិបាលប្រមែលប្រមូលក្នុងប្រទេស ដូចជា៖ ពន្ធប្រាក់ខែ ពន្ធលើប្រាក់ចំណូល ពន្ធដីធ្លី និងប្រភេទពន្ធ អាករមួយចំនួនផ្សេងទៀត។ អ្វីដែលជាការកត់សម្គាល់គឺថា នៅគ្រាចុងក្រោយនេះរដ្ឋាភិបាលបានជំរុញការប្រមូលពន្ធអាករជាច្រើនប្រភេទទៀត។ ពន្ធទាំងនេះមិនថ្មីទេសម្រាប់ប្រទេសជឿនលឿនប៉ុន្តែសម្រាប់ប្រទេសក្រីក្រដូចកម្ពុជាទើបងើបចេញពីសង្គ្រាម ប្រភេទពន្ធនេះហាក់ដូចជាអំពើកថ្មីមួយទៀតសម្រាប់ប្រជាជនកម្ពុជា។

ហើយពន្ធលើប្រាក់បៀវត្សក៏ជាការដាក់សម្ពាធបន្ថែមលើ បុគ្គលិក កម្មករ និងមន្ត្រីរាជការ អ្វីដែលថ្មីនោះគឺ ពន្ធចំណេញលើមូលធន។

នៅក្នុងប្រទេសគោរពច្បាប់ ការបង់ពន្ធគឺជាកាតព្វកិច្ចមិនអាចគេចវេះបានសម្រាប់ប្រជាពលរដ្ឋគ្រប់រូប ប៉ុន្តែសម្រាប់ប្រទេសកម្ពុជាវិញ កាតព្វកិច្ចបង់ពន្ធមិនថាពន្ធគយ ឬពន្ធដារទេមានការធូរលុង។ ឈ្មួញមួយចំនួនព្យាយាមមិនបង់ពន្ធក្នុងខណៈពេលដែលឈ្មួញមួយចំនួនផ្សេងទៀតសុខចិត្តបង់ពន្ធតាមការទាមទាររបស់រដ្ឋ។

ចំពោះពន្ធលើប្រាក់ខែនិងពន្ធលើអចលទ្រព្យដីធ្លីផ្ទះសម្បែង គេសង្កេតឃើញថាប្រជាជនមួយចំនួនចាប់ផ្តើមយល់ដឹងពីកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ។ ពួកគេខ្នះខ្នែងបំពេញក្រដាសស្នាមខ្លួនឯង ហើយយកប្រាក់ទៅបង់ជូនរដ្ឋ ប៉ុន្តែប្រជាជនខ្លះទៀតនៅធ្វើប្រងើយកន្តើយនឹងរឿងនេះនៅឡើយ។ ភាពប្រងើយកន្តើយរបស់ប្រជាពលរដ្ឋនេះ គឺមិនមែនកើតឡើងដោយសារពួកគេនោះទេ។

តាមពិតដោយសារប្រជាជនមួយចំនួននៅចោទសំនួរថាតើប្រាក់ដែលបង់ពន្ធជូនរដ្ឋនេះវាទៅណា? ហើយគេយកទៅធ្វើអ្វីពិតប្រាកដ? តើការប្រមែលប្រមូលពន្ធមានតម្លាភាពដែររឺទេ?

ជាធម្មតា ការប្រមូលពន្ធមិនថានៅប្រទេសជឿនលឿនគោរពច្បាប់ ឬនៅកម្ពុជាទេ ជាគោលការណ៍គឺសម្រាប់បម្រើផលប្រយោជន៍របស់រដ្ឋ មានន័យថាជាមួយទឹកប្រាក់ពន្ធនេះរដ្ឋាភិបាលត្រូវយកទៅចំណាយសម្រាប់កសាងផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ និងសម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធដទៃទៀត។ ម្យ៉ាងវិញទៀត ទឹកប្រាក់មួយចំណែកត្រូវរក្សាទុកសម្រាប់ប្រាក់ចូលនិវត្តន៍នៃមន្ត្រីរាជការ។

សម្រាប់ប្រទេសកម្ពុជា ដោយសារតែការបង់ពន្ធជាវប្បធម៌ថ្មី និងដោយសារតែការមិនទុកចិត្តលើសេវារបស់រដ្ឋនេះ ប្រជាពលរដ្ឋនៅអលអែក និងចោទជាសំនួរមិនចេះចប់មិនចេះហើយជុំវិញបញ្ហាបង់ពន្ធនេះ។

អ្នកខ្លះបន្តសំនួរថា ប្រសិនបើគេបង់ពន្ធជូនរដ្ឋគ្រប់ប្រភេទពន្ធទាំងអស់ តើពួកគេអាចទទួលបានអ្វីពីរដ្ឋវិញនៅពេលដែលពួកគេចូលនិវត្តន៍នោះ? ពន្ធចេះតែបង់តែពេលចាស់ទៅរដ្ឋាភិបាលគ្មានបានគិតគូរអ្វីសោះ។

សម្រាប់មន្ត្រីរាជការរដ្ឋ ពួកគេអាចទទួលបានប្រាក់ចូលនិវត្តន៍ខ្លះ តែចំពោះបុគ្គលិកអង្គការ ក្រុមហ៊ុនឯកជនវិញ តើពួកគេរំពឹងបានអ្វីពីរដ្ឋាភិបាល?

សរុបសេចក្តីមកវិញ ដើម្បីឱ្យប្រជាពលរដ្ឋមានទំនុកចិត្តហើយចូលរួមបង់ពន្ធដើម្បីកសាងប្រទេសជាតិយន្តការនៃការប្រមូលពន្ធត្រូវធ្វើឡើងដោយតម្លាភាពពន្ធត្រូវបំរើផលប្រយោជន៍ជាតិ និងរបស់ប្រជាជន។ ប្រាក់ចំណូលបានមកពីពន្ធដារ ឬពន្ធគយត្រូវតែចូលទៅក្នុងបេឡារដ្ឋ ពោលគឺមិនមែនចូលក្នុងហោប៉ៅរបស់បុគ្គលណាឡើយ?

ការប្រមូលចំណូលពីវិស័យពន្ធដារក្នុងឆ្នាំ២០២២កន្លងមកសម្រេចលើសផែនការប្រមាណជា ១០% ទៅ១៥% នេះបើយោងតាមសេចក្តីប្រកាសព័ត៌មានរបស់អគ្គនាយដ្ឋានពន្ធដារ (GDT)។ របាយការណ៍នៃកិច្ចប្រជុំបូកសរុបលទ្ធផលចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ បាននិយាយថាកំណើនសេដ្ឋកិច្ច និងការវិនិយោគបានធ្វើឱ្យការប្រមូលចំណូលពន្ធ អាកររបស់អគ្គនាយកដ្ឋានពន្ធដារបន្តកើនឡើងជារៀងរាល់ឆ្នាំ។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

តាមការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយលើការអនុវត្តន៍ជាក់ស្តែងគឺការវិភាគដែលមានសារៈសំខាន់បំផុតក្នុងការវាយតម្លៃ វាស់វែងពីដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីឱ្យដឹងពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួន ហើយនិងចេះកែប្រែចំណុចខ្សោយឱ្យទៅជាចំណុចខ្លាំង ពេលនោះហើយប្រទេសជាតិនឹងមានការរីកចម្រើនទៅមុខជានិរន្តរ៍។

## ៤.១ ការវិភាគលើចំណុចខ្លាំង

បន្ទាប់ពីបានធ្វើការស្រាវជ្រាវកន្លងមក ទៅលើការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ ខ្ញុំបាទបានវិភាគឃើញទៅលើចំណុចខ្លាំងមួយចំនួនមានដូចជា៖

- ការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ មានការកើនឡើងជាលំដាប់ដោយសារតែមូលហេតុមួយចំនួនដូចជា ការពង្រឹងការអនុវត្តវិធានការប្រមូលពន្ធប្រកបដោយតម្លាភាព និងប្រសិទ្ធភាពការរីកចម្រើននៃជីវភាពរបស់ប្រជាជន ដែលធ្វើឱ្យការប្រើប្រាស់មានការកើនឡើង។
- បច្ចុប្បន្នទោះបីចំនួនអ្នកជាប់ពន្ធមានការថយចុះក៏ពិតមែន ក៏ប៉ុន្តែចំនួនប្រាក់ពន្ធដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាននៅតែមានការកើនឡើងជាលំដាប់ ដែលអាចបង្ហាញឱ្យឃើញថាវិធានការនៃការប្រមូលពន្ធពិតជាមានប្រសិទ្ធភាព មួយវិញទៀតជីវភាពរបស់ប្រជាជនមានកើនឡើងផងដែរ។
- អគ្គនាយកដ្ឋានពន្ធដារតែងតែបង្កើតនូវសិក្ខាសាលាណែនាំដល់អ្នកជាប់ពន្ធឱ្យយល់ដឹងពីកាតព្វកិច្ច និងសិទ្ធិរបស់ពួកគេចំពោះរដ្ឋ ក៏ដូចជាចំណេះដឹងទាក់ទងនិងពន្ធដារ ដើម្បីធ្វើការបង់ប្រាក់និងដាក់លិខិតប្រកាសពន្ធឱ្យបានត្រឹមត្រូវ។
- អគ្គនាយកដ្ឋានពន្ធដារ តែងតែអនុវត្តនូវយុទ្ធសាស្ត្ររបស់ខ្លួនក្នុងការផ្តល់ជាការបង្រៀនបន្ថែមដល់មន្ត្រីពន្ធ ក្នុងការផ្តល់សេវាកម្មពន្ធដារ និងការផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធតាមរយៈការធ្វើកំណែទម្រង់ពាក់ព័ន្ធនិង ការធ្វើទំនើបកម្មបច្ចេកវិទ្យារួមមានការបង្ហោះច្បាប់អនុក្រឹត្យ ប្រកាសនិងព័ត៌មានផ្សេងៗ ទាក់ទងនិងពន្ធដារ នៅលើគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ ការចុះបញ្ជីនិងការប្រកាសបង់ប្រាក់ពន្ធតាម Online ជាដើម។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ទន្ទឹមនិងភាពវិជ្ជមានដែលលើកឡើងខាងលើ តាមរយៈការស្រាវជ្រាវរបស់ខ្ញុំក៏មើលឃើញថាពីកង្វះខាតមួយចំនួនដែលតម្រូវឱ្យមានការយកចិត្តដាក់បន្ថែមដើម្បីឱ្យការប្រមូលអាករបំភ្លឺសាធារណៈកាន់ប្រសើរឡើងដូចជា៖

- កង្វះមន្ត្រីពន្ធដារផ្តល់សេវាដល់អ្នកជាប់ពន្ធ ជាពិសេសនៅពេលដែលចំនួនអ្នកមកប្រកាសពន្ធមានចំនួនច្រើន ពួកគេត្រូវចាំរយៈពេលយូរ ហើយមន្ត្រីទទួលលិខិតប្រកាស មិនមានពេលភ្លាមៗក្នុងការបញ្ចូលទិន្នន័យនៅក្នុងលិខិតប្រកាសទៅក្នុងប្រព័ន្ធកត់ត្រាផ្ទៃក្នុងរបស់ពន្ធដារ ដែលធ្វើឱ្យពួកគាត់

មិនអាចដឹងភ្លាមៗថាការគណនាពន្ធរបស់អ្នកជាប់ពន្ធត្រឹមត្រូវដែរ ឬទេហើយបើមានកំហុងឆ្គងក្នុងការគណនា ក្រោយមន្ត្រីពន្ធបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធកត់ត្រាផ្ទៃក្នុង ហើយទើបដឹងហើយមន្ត្រីពន្ធធ្វើការជូនដំណឹងឱ្យអ្នកជាប់ពន្ធមកធ្វើការកែតម្រូវដែលធ្វើឱ្យអ្នកជាប់ពន្ធត្រូវចំណាយពេលច្រើនក្នុងដំណើរការដាក់លិខិតប្រកាសមួយឱ្យបានត្រឹមត្រូវ។

- អ្នកជាប់ពន្ធធ្វើការដាក់លិខិតប្រកាសច្រើនកុះករក្នុងអំឡុងថ្ងៃជិតផុតកំណត់ ដែលជាហេតុធ្វើឱ្យមានការកកស្ទះខ្លាំងក្នុងរយៈពេលប៉ុន្មានថ្ងៃចុងក្រោយ។
- ដំណើរការនៃការបង់ប្រាក់ពន្ធនៅមានភាពយឺតយ៉ាវនៅឡើយ។ ដោយសារតែប្រតិបត្តិការនៃការបង់ប្រាក់ពន្ធនៅមានភាពមិនច្បាស់លាស់ពីបែបបទ និងវិធីសាស្ត្រនៃការគណនានៅឡើយ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

យោងតាមការសិក្សាកន្លងមកខ្ញុំបាទសង្កេតឃើញថា ការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារមានការកើនឡើងជាលំដាប់ដោយសារតែមូលហេតុមួយចំនួនដូចជា ការកើនឡើងនៃចំនួនអ្នកជាប់ពន្ធ ការពង្រឹងការអនុវត្តន៍វិធានការប្រមូលពន្ធប្រកបដោយតម្លាភាពនិងប្រសិទ្ធភាព ការរីកចម្រើននៃជីវភាពរបស់ប្រជាជានដែលធ្វើការប្រើប្រាស់មានការកើនឡើង។ ទាំងនេះក៏ដោយសារការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំដែលតែងតែបង្កើតនូវសិក្ខាសាលាណែនាំដល់អ្នកជាប់ពន្ធឱ្យយល់ដឹងពីកាតព្វកិច្ចនិងសិទ្ធិរបស់ពួកគេចំពោះរដ្ឋ ក៏ដូចជាចំណេះដឹងទាក់ទង និងពន្ធដារដើម្បីធ្វើការបង់ប្រាក់ពន្ធនិងដាក់លិខិតប្រកាសពន្ធឱ្យបានត្រឹមត្រូវ។ ម៉្យាងវិញទៀតសមិទ្ធិផលនេះក៏ដោយសារតែយុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋានពន្ធដារក្នុងការផ្តល់ការបង្រៀនបន្ថែមដល់មន្ត្រីពន្ធ ក្នុងការផ្តល់សេវាកម្មពន្ធដារនិងការផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធ តាមរយៈការធ្វើកំណែទម្រង់ពាក់ព័ន្ធ និងការធ្វើទំនើបកម្មបច្ចេកទេសព័ត៌មានវិទ្យា។

ជារួមនិតិវិធីនៃការប្រមូលអាករបំភ្លឺសាធារណៈ និងការបង់ពន្ធមានលក្ខណៈស្មុគស្មាញខ្លាំង ដែលតម្រូវឱ្យអ្នកជាប់ពន្ធទាំងអស់ធ្វើការសិក្សា និងស្វែងយល់ឱ្យស៊ីជម្រៅ។ ម៉្យាងវិញទៀតតាមរយៈភាពវិជ្ជមាននៃកំណើនប្រាក់ពន្ធ កំណើននៃការប្រើប្រាស់ កំណើននៃការផលិត ការខិតខំប្រឹងប្រែង និងគោរពច្បាប់របស់ភាគីដែលពាក់ព័ន្ធ ដែលមានភាពប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ តាមរយៈការវិភាគនូវលទ្ធផលជាគំរូរបស់អគ្គនាយកដ្ឋានពន្ធដារខាងលើ និងកត្តាផ្សេងៗទៀតដែលជះឥទ្ធិពលដល់បម្រែបម្រួលភាគីដែលពាក់ព័ន្ធដែលមានភាពប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំតាមរយៈការវិភាគនូវលទ្ធផល ក្លាយជាផ្នែកមួយដ៏សំខាន់ដែលជំរុញឱ្យសេដ្ឋកិច្ចប្រទេសកម្ពុជាមានការអភិវឌ្ឍន៍ដោយសារតែរាជរដ្ឋាភិបាលអាចមាននូវថវិកាគ្រប់គ្រាន់ដើម្បីទ្រទ្រង់ដល់ការចំណាយផ្សេងៗនៅក្នុងប្រទេស។

## ៥.២ ការផ្តល់អនុសាសន៍

យោងតាមរយៈការសន្និដ្ឋានខាងលើ ខ្ញុំបាទសង្កេតឃើញថាអគ្គនាយកដ្ឋានពន្ធដារបានរៀបចំយុទ្ធសាស្ត្រកៀគរចំណូលយ៉ាងមានប្រសិទ្ធភាព ទាំងតាមរយៈការផ្តល់ចំណេះដឹង និងផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធ តាមរយៈការវិវត្តន៍នូវបច្ចេកវិទ្យាថ្មីភ្ជាប់នៅលើគេហទំព័រ របស់អគ្គនាយកដ្ឋានពន្ធដារ។ ខ្ញុំបាទសូមគាំទ្រ និងលើកទឹកចិត្តដល់ខាងអគ្គនាយកដ្ឋានពន្ធដារ ក្នុងការបន្តនូវបេសកកម្មរបស់ខ្លួនក្នុងការអភិវឌ្ឍន៍បច្ចេកវិទ្យា និងពង្រឹងនីតិវិធីឱ្យកាន់តែប្រសើរឡើងថែមទៀត។ ទន្ទឹមនឹងនេះផងដែរអគ្គនាយកដ្ឋានពន្ធដារគួរតែកែលម្អនូវចំណុចខ្វះខាតដូចខាងក្រោម៖

- អគ្គនាយកដ្ឋានពន្ធដារគួរតែបន្ថែមចំនួនមន្ត្រីពន្ធ ដើម្បីឱ្យការទទួលលិខិតប្រកាសពន្ធប្រកបដោយភាពរលូន និងរហ័សទាន់ចិត្តសម្រាប់អ្នកជាប់ពន្ធ។ ក្នុងនោះដែរអ្នកជាប់ពន្ធ

ទាំងឡាយក៏គួរតែចូលរួមសហការ និងមានមនសិកាដាស់តឿនខ្លួនឯងពីភារកិច្ច ដែលខ្លួនត្រូវបំពេញដើម្បីឆ្លើយតបទៅនឹងការខិតខំប្រឹងប្រែងរបស់ខាងពន្ធដារដូចគ្នា។

- ដើម្បីបណ្តុះគំនិតដល់ក្មេងជំនាន់ក្រោយខាងអគ្គនាយកដ្ឋានពន្ធដារគួរតែស្នើសុំដល់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការដាក់បញ្ចូលនូវមុខវិជ្ជាពន្ធដារទៅក្នុងកម្មវិធីសិក្សា ដើម្បីឱ្យពួកគេមានការយល់ដឹងពីពន្ធដារ ពិសេសគឺដឹងពីគោលបំណង និងសារៈប្រយោជន៍នៃការប្រមូលពន្ធ ព្រមទាំងភាពជាពលរដ្ឋក្នុងការចូលរួមគោរពច្បាប់ទាក់ទង និងការបង្កើតអាជីវកម្មផ្សេងៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- អគ្គនាយកដ្ឋានពន្ធដារគួរតែធ្វើសិក្ខាសាលា ដើម្បីផ្តល់ចំណេះដឹងដល់អ្នកជាប់ពន្ធឱ្យបានច្រើនឱ្យពួកគេយល់ច្បាស់ពីដំណើរការនៃការបង់ពន្ធ និងវិធីសាស្ត្រនៃការគណនាពន្ធឱ្យបានត្រឹមត្រូវជាហេតុនាំឱ្យខាតពេលវេលាទាំងមន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធក្នុងការកែប្រែលិខិតប្រកាស។

# ឯកសារយោង

# ឯកសារយោង

ឯកសារយោង ឯកសារផ្សេងៗក្នុងបណ្ណាល័យនៃ វិទ្យាស្ថាន វ៉ាន់ដា ទាក់ទងនិង អាការបំភ្លឺសាធារណៈ ដកស្រង់ចេញពីសៀវភៅច្បាប់ស្តីពីសារពើពន្ធរបស់អគ្គនាយកដ្ឋានពន្ធ

- [1] សាលាជាតិពន្ធដារៈ វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈពន្ធដារជំនាន់ ១៧ មេរៀនអាករបំភ្លឺសាធារណៈ ទំព័រលេខ ៥៤
- [1] www.tax.gov.kh (10 12 2023)
- [1] https://web.facebook.com/ReanAccounting/ (10 12 2023)
- [1] សាលាជាតិពន្ធដារៈ វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈពន្ធដារជំនាន់ ១៧ មេរៀនសេចក្តីផ្តើមនៃការប្រមូលពន្ធ ទំព័រទី ៤
- [1] https://www.tax.gov.kh (15 12 2023)
- [1] វិទ្យាស្ថានវ៉ាន់ដាៈ របាយការណ៍បញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់របស់និស្សិតជំនាន់ ១៨ ឈ្មោះវ៉ែន វដ្ឋា ទំព័រទី ៩
- [1] https://cambotax.com (13 01 2024)
- [1] សៀវភៅច្បាប់ស្តីពីសារពើពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ ត្រង់ទំព័រទី ២៥

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ







| | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 |
|---|---|---|---|---|---|---|---|
| អពដ | 14.8% | 17.2% | 22.0% | 20.7% | 12.1% | 19.0% | 26.0% |
| អគរ | 14.0% | 13.8% | 26.1% | 10.0% | 14.0% | 9.2% | |

CS Scanned with CamScanner

## ២- គោលការណ៍រួមនៃកំណែទម្រង់ប្រព័ន្ធពន្ធដារ(២០១៩-២០២៣)

**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤**
(Rectangular Strategy Phase4)

↓

**កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
(PFMRP)

↓

**យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣**
(RMS)

↓

**ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ ២០១៩-២០២៣របស់អគ្គនាយកដ្ឋានពន្ធដារ**
(SP & OP)



**អភិបាលកិច្ចល្អ**
(Good Governance)

**រដ្ឋបាលកិច្ចល្អ**
(Good Administration)

**ប្រសិទ្ធភាពនៃភាពជាអ្នកដឹកនាំ**
(Effective Leadership & Management)

**គុណធិបតេយ្យ**
(Meritocracy)

គោលបំណងជាយុទ្ធសាស្ត្រ៖

- គោលបំណងទី១៖ បង្កើនអនុលោមភាពតាមច្បាប់ដោយស្ម័គ្រចិត្ត និងកាត់បន្ថយជាអតិបរមានូវបន្ទុកអ្នកជាប់ពន្ធ ដោយផ្តល់សេវាប្រកបដោយគុណភាព
- គោលបំណងទី២៖បន្តពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ប្រកបដោយភាពទន់ភ្លន់ ម៉ឺងម៉ាត់ និងស្មើភាព ដើម្បីជំរុញអ្នកជាប់ពន្ធ ឱ្យបំពេញកាតព្វកិច្ចសារពើពន្ធបានត្រឹមត្រូវ
- គោលបំណងទី៣៖ អនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយ

## ២- គោលការណ៍រួមនៃកំណែទម្រង់ប្រព័ន្ធពន្ធដារ




CS Scanned with CamScanner